**ឯកសារស្រាវជ្រាវ**

គណៈកម្មការទី១ ព្រឹទ្ធសភា ទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

# សិទ្ធិ និងសុខុមាលភាពរបស់ជនជាតិដើមភាគតិចនៅកម្ពុជា

អ្នកស្រាវជ្រាវ៖ **អាប់ចូរិនសុិន សេបាស្សៀន**

ខែតុលា ឆ្នាំ២០១៤

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា


មាតិកា ........ 2

ខ្លឹមសារសង្ខេប ........ 3

សេចក្តីផ្តើម ........ 7

១. ការទទួលបានការអប់រំ ........ 10
  ១.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ - បញ្ហា និងដំណោះស្រាយ ........ 13
  ១.២. ការស្រាវជ្រាវនៅមូលដ្ឋាន ........ 16

២. ការទទួលបានសេវាថែទាំសុខភាព ........ 17
  ២.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ-បញ្ហា និងដំណោះស្រាយ ........ 20
  ២.២. ការស្រាវជ្រាវនៅមូលដ្ឋាន ........ 21

៣. ការចូលរួមនយោបាយរបស់ជនជាតិដើមភាគតិចក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ........ 22
  ៣.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ -បញ្ហា និងដំណោះស្រាយស ........ 23
  ៣.២. ការស្រាវជ្រាវនៅមូលដ្ឋាន ........ 24

៤. សិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច ........ 25
  ៤.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ-បញ្ហា និងដំណោះស្រាយ ........ 27
  ៤.២. ការចុះស្រាវជ្រាវដល់មូលដ្ឋាន ........ 32

សេចក្តីសន្និដ្ឋាន ........ 34

គន្ថនិទ្ទេស ........ 36

# ខ្លឹមសារសង្ខេប

ប្រទេសកម្ពុជាមានក្រុមជនជាតិដើមភាគតិចខុសៗគ្នាចំនួន១៧ក្រុម [1] ដែលតាមការប៉ាន់ស្មានមានចំនួនប្រមាណពី១ទៅ២%នៃចំនួនប្រជាជនសរុប [2] ។ ជនជាតិដើមភាគតិចទាំងនេះរស់នៅក្នុងខេត្តចំនួន១៨នៃខេត្តទាំង២៥របស់កម្ពុជា ដែលភាគច្រើនក្រុមជនជាតិដើមទាំងនេះប្រមូលផ្តុំគ្នារស់នៅខេត្តភាគខាងជើងនៃប្រទេសកម្ពុជា។ ជាមួយគ្នានេះ ប្រជាជនចំនួន៧១%ក្នុងខេត្តរតនៈគិរី និង៦៦%ក្នុងខេត្តមណ្ឌលគិរី គឺជាជនជាតិដើមភាគតិច ខណៈដែលនៅក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះវិញក៏មានចំនួនជនជាតិដើមភាគតិចជាច្រើនសន្ធឹកសន្ធាប់ផងដែរ[3]។

ក្រៅពីលិខិតតុបករណ៍អន្តរជាតិជាច្រើនដែលកម្ពុជាបានចូលរួមជាភាគីហត្ថលេខី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់នូវសិទ្ធិផ្លូវការស្មើភាពគ្នាដល់ប្រជាជនកម្ពុជាគ្រប់រូបដោយមិនរើសអើងពូជសាសន៍ ស្របពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ ផ្តល់សិទ្ធិកាន់កាប់ដីសម្ងហាភាពសម្រាប់ជនជាតិដើមភាគតិចផងដែរ[4]។ ផ្ទុយទៅវិញ ការស្រាវជ្រាវខាងក្រោមនេះស្នើឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធានាថា ជនជាតិដើមភាគតិចនៅកម្ពុជាទទួលបានសិទ្ធិជាប្រជាពលរដ្ឋ ដូចគ្នាទៅនឹងប្រជាពលរដ្ឋមិនមែនជនជាតិដើមភាគតិច ។

វិសមភាពនេះនឹងត្រូវធ្វើការវិភាគទាក់ទងទៅនឹងការទទួលបានសិទ្ធិរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ដែលមានដូចជា៖

១. ការទទួលបានការអប់រំ
២. ការទទួលបានសេវាថែទាំសុខភាព
៣. ការចូលរួមក្នុងវិស័យនយោបាយ
៤. សិទ្ធិកាន់កាប់ដីធ្លី

---

[1] **Diana Vinding** និងការិយាល័យពលកម្មអន្តរជាតិ, "*ទស្សនវិស័យពីបណ្តាសហគមន៍នានានៅប្រទេសបូលីវី កម្ពុជា កាមារូន កាតេម៉ាឡា និងណេប៉ាល់៖ ជនជាតិដើមភាគតិច និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍*", (ហ្សឺណែវ៖ អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០៦), ទំព័រ៧.

[2] **PrasenjitChakma,** "*ការធ្វើសមាហរណកម្មទស្សនវិស័យរបស់ជនជាតិដើមភាគតិចនៅក្នុងដំណើរការអភិវឌ្ឍប្រទេស៖ ការសិក្សាឡើងវិញ អំពី**CCAs**និង**UNDAFs**ដែលបានជ្រើសរើស*", (ញូវយ៉ក៖ វេទិការអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីពី បញ្ហាជនជាតិដើមភាគតិច ឆ្នាំ២០០៨), ទំព័រ២៤.

[3] ដូចឯកសារយោងខាងលើ, ទំព័រ២៥.

[4] វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, "*ជនជាតិដើមភាគតិចនៅកម្ពុជា*", (ភ្នំពេញ៖ វេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ឆ្នាំ២០០៦), ទំព័រ៣.

## លទ្ធផលសំខាន់ៗនៃការសិក្សា៖

សហគមន៍ជនជាតិដើមភាគតិចមួយចំនួននៅក្នុងប្រទេសកម្ពុជានៅតែទទួលបានសេវាអប់រំទាបជាងមធ្យមភាគនៃសេវាអប់រំទូទាំងប្រទេស។ ទោះជាយ៉ាងណា នេះគឺជាបញ្ហារ៉ាំរ៉ៃ និងពិបាកដោះស្រាយ។ គោលនយោបាយស្តីពីការអប់រំពីរភាសារបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការផ្តល់ជូនសេវាអប់រំជាភាសាខ្មែរ និងភាសាជនជាតិដើមផ្សេងៗដើម្បីឆ្លើយតបចំពោះបញ្ហានេះ គឺបាននឹងកំពុងសម្រេចបានលទ្ធផលជាទីមោទនៈ និងត្រូវបានទទួលស្គាល់ថាជាការអនុវត្តដ៏ល្អបំផុតប្រចាំតំបន់។

ជនជាតិដើមភាគតិចនៅកម្ពុជា មិនទាន់ទទួលបានសេវាថែទាំសុខភាពនៅឡើយទេ ទោះជាយ៉ាងណា យើងឃើញថា ស្ថានភាពនេះមានលក្ខណៈល្អប្រសើរឡើងជាងមុនគួរឲ្យកត់សម្គាល់នៅក្នុងរយៈពេល១០ឆ្នាំ ចុងក្រោយនេះ ហើយក៏នឹងនៅតែបន្តមានភាពប្រសើរឡើងជាបន្តបន្ទាប់នាពេលអនាគត។ ការបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ការឧបត្ថម្ភគាំទ្រដល់មន្ទីរព្យាបាលសុខភាពនានា និងការលុបបំបាត់ការទារថ្លៃសេវាថែទាំសុខភាពជាមុន គឺជាកត្តាចម្បងចំពោះការដោះស្រាយបញ្ហាវិសមភាពនេះ។

ការចូលរួមនយោបាយរបស់ជនជាតិដើមភាគតិចនៅតំបន់នានាដែលបានធ្វើការស្ទង់មតិ គឺមានលក្ខណៈល្អប្រសើរ។ គ្រប់ក្រុមប្រឹក្សាឃុំ/សង្កាត់នៃសហគមន៍ជនជាតិដើមភាគតិចទាំងនេះ មានសមាជិកក្រុមប្រឹក្សាជាជនជាតិដើមភាគតិចយ៉ាងច្រើនលើសលប់។ ជាងនេះទៀត សហគមន៍ជនជាតិដើមភាគតិចមួយចំនួនយល់ថាក្រុមប្រឹក្សាឃុំរបស់ខ្លួនបានធ្វើការផ្សារភ្ជាប់ពួកគាត់ទៅក្នុងដំណើរការនយោបាយ ខណៈដែលសហគមន៍ដែលបានធ្វើការស្ទាបស្ទង់មតិជាងពាក់កណ្តាលទៀត ក៏បានលើកឡើងថា អាជ្ញាធរខេត្តបានឆ្លើយតបទៅតាមតម្រូវការរបស់ខ្លួន ដែលប្រការនេះបានជំរុញឲ្យពួកគាត់ចូលរួមកាន់តែខ្លាំងទៅក្នុងប្រព័ន្ធនយោបាយរបស់កម្ពុជា។

សិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាបញ្ហាដ៏ស្មុគស្មាញបំផុតដែលបានកើតមានឡើង។ ប្រការនេះគឺដោយសារសហគមន៍ជនជាតិដើមភាគតិចមានទស្សនៈថា កិច្ចការពារព្រៃឈើគឺជាកត្តាដ៏សំខាន់បំផុតចំពោះភាពគង់វង្សនៃវប្បធម៌របស់ពួកគាត់ រីឯគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាតម្រូវឲ្យមានការប្រែក្លាយតំបន់ដាច់ស្រយាលច្រើនទៀតទៅជាតំបន់ដាំដុះផ្តល់ផលចំណូលខ្ពស់ថែមទៀត ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ដាច់ស្រយាល និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។ ខណៈដែល ជនជាតិដើមភាគតិចនៅកម្ពុជាទទួលបានសិទ្ធិកាន់កាប់ដីធ្លីយ៉ាងទូលំទូលាយនៅក្នុងច្បាប់ តែនៅក្នុងការអនុវត្តជាក់ស្តែង ដំណើរការនៃការចុះបញ្ជីសហគមន៍ជនជាតិដើមភាគ

តិច និងការទទួលបានកម្មសិទ្ធិកាន់កាប់ដីសមូហភាព គឺតែងតែមានភាពយឺតយ៉ាវជាខ្លាំង បើប្រៀបធៀបទៅនឹងល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច។ ផ្ទុយទៅវិញ ស្រុកពេជ្រចិន្តានៃខេត្តមណ្ឌលគិរី គឺជាឧទាហរណ៍ដ៏ល្អ ដោយនៅទីនោះសហគមន៍ជនជាតិដើមភាគតិចនានាពេញចិត្តជាខ្លាំងជាមួយនឹងកិច្ចការពាររបស់រាជរដ្ឋាភិបាលចំពោះព្រៃសហគមន៍របស់ខ្លួន ស្របពេលជាមួយគ្នានោះ ក៏មានការអភិវឌ្ឍសេដ្ឋកិច្ចខ្លាំងផងដែរ ដូចជា ដំណាំកៅស៊ូ ដែលជាគោលគំនិតដ៏សំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍបច្ចុប្បន្នរបស់កម្ពុជា។ ស្ថានភាពនេះហាក់បង្ហាញពីការផ្តល់នូវការសម្របសម្រួលមួយរវាងផលប្រយោជន៍របស់សហគមន៍ជនជាតិភាគតិចនានានៅក្នុងមូលដ្ឋាន ជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែទូលាយរបស់ប្រទេស ដែលអាចជម្រុញឲ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀត។

## មូលហេតុនៃការស្រាវជ្រាវៈ

ឯកសារនេះត្រូវបានរៀបចំដើម្បីឆ្លើយតបចំពោះសេចក្តីស្នើរបស់គណៈកម្មការទី១នៃព្រឹទ្ធសភា សម្រាប់ឯកសារស្រាវជ្រាវស្តីពីសិទ្ធិជនជាតិដើមភាគតិច។ នេះមានន័យថាជំនួសឲ្យការផ្តល់នូវព័ត៌មានលម្អិតស្តីពីស្ថានភាពនៃសិទ្ធិជាក់លាក់នានានៅក្នុងបណ្តាខេត្តដែលបានស្នើឡើង ដូចជា ខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី ស្ថានភាពនៃសិទ្ធិនានាដែលបានកំណត់ថាចាំបាច់បំផុតចំពោះជនជាតិដើមភាគតិចនៅកម្ពុជាត្រូវបានយកមកពិភាក្សានៅក្នុងបរិបទទូលំទូលាយជាងមុន។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ដោយផ្អែកលើហេតុផលពីរយ៉ាង។ ទី១-ការស្រាវជ្រាវកន្លងមកទៅលើប្រធានបទនានាពាក់ព័ន្ធនឹងបញ្ហានីមួយៗខាងលើក្នុងបរិបទប្រទេសកម្ពុជាទាំងមូល កត់សម្គាល់ឃើញថា បញ្ហានានាដែលជនជាតិដើមភាគតិចជួបប្រទះនៅក្នុងខេត្តនីមួយៗគឺមានលក្ខណៈស្រដៀងគ្នាស្ទើរតែទាំងស្រុង។ ទី២-ដោយសារខេត្តកំពង់ចាមពុំមានជនជាតិដើមភាគតិចច្រើន ហើយខេត្តនេះក៏ពុំមានព័ត៌មានស្តីពីបញ្ហាជនជាតិដើមភាគតិច ហេតុនេះវិធីសាស្ត្រនេះត្រូវបានចាត់ទុកថាផ្តល់ព័ត៌មានសម្បូរបែប និងមានអត្ថប្រយោជន៍ជាង ចំពោះគណៈកម្មការ។ ដើម្បីគាំទ្រចំពោះការស្រាវជ្រាវដ៏ទូលាយនេះ វិទ្យាស្ថានសភាកម្ពុជាបានអនុវត្តន៍វិធីសាស្ត្រចុះស្រាវជ្រាវដល់មូលដ្ឋានដើម្បីចងក្រងករណីសិក្សានានាស្តីពីស្ថានភាពសិទ្ធិជនជាតិដើមភាគតិច ក្នុងគោលបំណងផ្តល់ជូនគណៈកម្មការនូវព័ត៌មានពិស្តារ និងព័ត៌មានថ្មីបំផុតតាមដែលអាចធ្វើបាន។ ការចុះស្រាវជ្រាវដល់មូលដ្ឋាននេះ ត្រូវបានធ្វើឡើងនៅស្រុកពេជ្រចិន្តាក្នុងខេត្តមណ្ឌលគិរី និងស្រុកអណ្តូងមាស និងស្រុកបរកែវនៃខេត្តរតនៈគិរី។ តំបន់ទាំងនេះត្រូវបានបង្ហាញនៅក្នុងផែនទី ១ ខាងក្រោមនេះ។ បើទោះបីជាខេត្តរតនៈគិរី មិនត្រូវបានបញ្ចូលនៅក្នុងសេចក្តីស្នើរបស់គណៈកម្មការក្តី តែខេត្តរតនៈគិរីនេះត្រូវបានយកមកធ្វើការសិក្សា ដោយសារខេត្តនេះគឺជាខេត្តដែលមានចំនួនសមាមាត្រជនជាតិដើមភាគតិចច្រើន

បំផុតនៅកម្ពុជា និងជាទីកន្លែងដែលបញ្ហាសិទ្ធិជនជាតិដើមភាគតិចត្រូវបានគេយកមកធ្វើការសិក្សាស្រាវជ្រាវច្រើនបំផុតរួចមកហើយ។

សិទ្ធិមួយចំនួនដូចខាងក្រោមត្រូវបានជ្រើសរើសមកស្រាវជ្រាវ ដោយយោងលើមូលហេតុពីរយ៉ាង គឺដោយសារសិទ្ធិទាំងនេះត្រូវបានកំណត់ថាពាក់ព័ន្ធខ្លាំងចំពោះជនជាតិដើមភាគតិចនៅកម្ពុជា ហើយសិទ្ធិទាំងនេះអាចវាយតម្លៃបាន និងត្រូវបានស្នើឡើងដោយគណៈកម្មការ។ ប៉ុន្តែ ចំពោះសេចក្តីស្នើជាក់ស្តែងរបស់គណៈកម្មការ គឺពុំអាចធ្វើបាននោះទេក្នុងការសិក្សាទៅលើបញ្ហាយុត្តិធម៌ និងពន្ធនាគារពាក់ព័ន្ធនឹងជនជាតិដើមភាគតិចដែលបានស្នើឡើង។ ដោយសារបញ្ហាពេលវេលា ទំហំនិងសារៈសំខាន់នៃបញ្ហានេះ យើងមិនអាចធ្វើការសិក្សាដល់មូលដ្ឋាន និងស្រាវជ្រាវលើប្រធានបទនេះ និងចំណុចផ្សេងទៀតដែលបានស្នើនោះទេ។ ប៉ុន្តែ វិទ្យាស្ថានសភាកម្ពុជាកំពុងអនុវត្តន៍គម្រោងស្រាវជ្រាវមួយ ស្តីពីការគ្រប់គ្រងពន្ធនាគារ ដែលនឹងដាក់បង្ហាញជូនគណៈកម្មការក្នុងពេលឆាប់ៗខាងមុខនេះ។ ទីពីរ បើទោះបីជា គណៈកម្មការបានស្នើព័ត៌មានស្តីពីឱកាសទទួលបានសិទ្ធិតាំងទីលំនៅរបស់ជនជាតិដើមភាគតិចក្តី តែការស្រាវជ្រាវប្រភេទទីពីរ និងការចុះស្រាវជ្រាវដល់មូលដ្ឋានជាបន្តបន្ទាប់បានបង្ហាញថា កត្តាសំខាន់បំផុតដែលជះឥទ្ធិពលចំពោះការតាំងទីលំនៅរបស់ជនជាតិដើមភាគតិច គឺសិទ្ធិកាន់កាប់ដីធ្លី ហេតុដូចនេះហើយសិទ្ធិនេះត្រូវបានយកមកសិក្សាជំនួសវិញ។

# សេចក្តីផ្តើម

ឯកសារនេះនឹងធ្វើការសិក្សាលើបួនចំណុចពាក់ព័ន្ធនឹងសិទ្ធិ និងសុខុមាលភាពរបស់ជនជាតិដើមភាគតិច៖ ការទទួលបានការអប់រំ ការទទួលបានសេវាថែទាំសុខភាព ការចូលរួមនយោបាយ និងសិទ្ធិកាន់កាប់ដីធ្លី។ ទិដ្ឋភាពទូទៅនៃប្រធានបទនីមួយៗ និងបញ្ហាប្រឈមបច្ចុប្បន្ននឹងត្រូវបានលើកឡើង រួមជាមួយនឹងលទ្ធផលនៃការចុះស្រាវជ្រាវដល់មូលដ្ឋាននាពេលថ្មីៗកន្លងទៅរបស់វិទ្យាស្ថានសភាកម្ពុជា។ ការចុះស្រាវជ្រាវដល់មូលដ្ឋានត្រូវបានធ្វើឡើងនៅស្រុកអណ្តូងមាស និងស្រុកបរកែវ ខេត្តរតនៈគិរី និងស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគិរី ដូចមានបង្ហាញក្នុងផែនទី១ ខាងក្រោម។




*ផែនទី ១៖ បណ្តាស្រុកនៅក្នុងខេត្តរតនៈគរី និងមណ្ឌលគិរី ដែលការចុះស្រាវជ្រាវដល់មូលដ្ឋានបានធ្វើឡើង*[5]

[5] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, "*សៀវភៅផែនទីសេដ្ឋកិច្ចសង្គមរបស់កម្ពុជា*", (ភ្នំពេញ៖ អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ឆ្នាំ២០១៤), http://www.opendevelopmentcambodia.net/maps/ .

ជាទូទៅ សូចនាករលើវិស័យសុខាភិបាល ការអប់រំ និងការកាន់កាប់ដីធ្លី របស់ជនជាតិដើមភាគតិចនៅកម្ពុជាមានកម្រិតទាបជាងសូចនាករមធ្យមថ្នាក់ជាតិ លើកលែងតែសូចនាករនៃការចូលរួមនយោបាយមួយគត់។ ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងនានាត្រូវបានធ្វើឡើងដើម្បីបំពេញនូវគម្លាតទាំងនេះ ដើម្បីធ្វើឱ្យសូចនាករទាំងនេះមានកម្រិតស្មើគ្នា ហើយកន្លងមកវិស័យអប់រំបានទទួលភាពជោគជ័យជាងគេធៀបនឹងវិស័យដទៃទៀត។ បច្ចុប្បន្ន កម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសនាំមុខគេក្នុងតំបន់ លើការផ្តល់កម្មវិធីអប់រំដ៏មានប្រសិទ្ធភាពដល់ជនជាតិដើមភាគតិចរបស់ខ្លួន។ ជាមួយគ្នានោះផងដែរ បញ្ហាសុខភាពក៏បាននៅតែបន្តធ្វើឲ្យប្រសើរឡើងជាបណ្តើរៗផងដែរ។ រីឯសិទ្ធិកាន់កាប់ដីធ្លីវិញមានលក្ខណៈស្មុគស្មាញជាងគេ។

ការទទួលបានការអប់រំរបស់ជនជាតិដើមភាគតិចមានកម្រិតទាបគួរឱ្យព្រួយបារម្ភ ធៀបនឹងមធ្យមភាគទូទាំងប្រទេសកម្ពុជា។ ប៉ុន្តែ ជាងដប់ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តព្យាយាមដោះស្រាយបញ្ហានេះ តាមរយៈការបង្កើតឲ្យមានកម្មវិធីអប់រំពីរភាសា ជាភាសាជនជាតិដើមភាគតិចផង និងជាភាសាខ្មែរផង ហើយវិធានការនេះទទួលបានលទ្ធផលបឋមគួរឱ្យកត់សម្គាល់។ បច្ចុប្បន្ន កម្មវិធីលើកកម្ពស់សិទ្ធិទទួលបានការអប់រំរបស់ជនជាតិដើមភាគតិចត្រូវបានទទួលស្គាល់ថាជាការអនុវត្តដ៏ល្អសម្រាប់តំបន់។ ការចុះស្រាវជ្រាវដល់មូលដ្ឋានបញ្ជាក់អំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំនេះផងដែរ។

ជនជាតិដើមភាគតិចនៅកម្ពុជាទទួលបានសេវាថែទាំសុខភាពទាបជាងកម្រិតមធ្យមដែលប្រជាជនទូទៅទទួលបាន។ មូលហេតុនេះបណ្តាលមកពីកត្តាមួយចំនួនដូចជា ភាពដាច់ស្រយាលរវាងសហគមន៍នឹងមណ្ឌលសុខភាព មិនមានថវិកាគ្រប់គ្រាន់សូម្បីតែសម្រាប់ការចំណាយតិចតួចលើសេវាព្យាបាល ឬមធ្យោបាយធ្វើដំណើរដើម្បីទទួលសេវាព្យាបាល និងការបន្តការព្យាបាលតាមបែបប្រពៃណីជនជាតិ។ ផ្ទុយទៅវិញ ការចុះស្រាវជ្រាវដល់មូលដ្ឋានបានរកឃើញថា ទោះបីជាចំណុចទាំងនេះនៅតែជាបញ្ហាក៏ដោយ ក៏សហគមន៍ជនជាតិដើមភាគតិចបានឲ្យដឹងថា ពួកគាត់ទទួលបានសេវាថែទាំសុខភាពមូលដ្ឋាន យល់ដឹងអំពីអនាម័យ និងបញ្ហាសុខភាពនានា គួរឱ្យកត់សម្គាល់ជាងមុន នៅក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ។

កង្វល់ស្តីពីការចូលរួមនយោបាយរបស់ជនជាតិដើមភាគតិច ត្រូវបានដោះស្រាយតាមរយៈការសិក្សាអំពីការចូលរួម និងការយល់ឃើញរបស់ជនជាតិដើមភាគតិចចំពោះក្រុមប្រឹក្សាឃុំនានា និងរដ្ឋបាលខេត្ត។ ការសិក្សាព័ត៌មានឡើងវិញបានបង្ហាញថាការចូលរួមនេះគឺបានផ្តល់អត្ថប្រយោជន៍ជាច្រើន ដោយសារតែការចូលរួមនេះ ធ្វើឲ្យសហគមន៍ជនជាតិដើមភាគតិចមានឥទ្ធិពលលើគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការគាំទ្រពួកគាត់ ខណៈដែល

នឹងផ្តល់ឲ្យរដ្ឋាភិបាលនូវលទ្ធភាពកាន់តែទូលាយក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន និងគ្រប់គ្រងតំបន់ជនជាតិដើមភាគតិចប្រកបដោយប្រសិទ្ធភាព។ ការចុះស្រាវជ្រាវដល់មូលដ្ឋានបានរកឃើញថា នៅក្នុងសហគមន៍ជនជាតិដើមភាគតិចដែលយើងបានចុះទៅដល់ គ្រប់ក្រុមប្រឹក្សាឃុំនៃសហគមន៍ទាំងនោះមានសមាជិកភាគច្រើនជាជនជាតិដើមភាគតិច ហើយសហគមន៍ភាគច្រើនជាទូទៅ គឺពេញចិត្តចំពោះការចូលរួមនយោបាយដែលបានផ្តល់ឲ្យពួកគាត់នេះណាស់។ ជាងនេះទៅទៀត សហគមន៍ជនជាតិដើមភាគតិចនៅក្នុងស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគិរី បានលើកឡើងថា ពួកគាត់យល់ថារដ្ឋបាលខេត្តរបស់ខ្លួនពិតជាបានជួយជ្រោមជ្រែងយ៉ាងសកម្ម និងបានឆ្លើយតបទៅតាមតម្រូវការរបស់ខ្លួនទៀតផង។

ផ្នែកចុងក្រោយ គឺសិក្សាទៅលើបញ្ហាពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិចនៅកម្ពុជា។ ផ្នែកនេះ ចាប់ផ្តើមដោយការបង្ហាញពីទិដ្ឋភាពទូទៅនៃការទទួលបានសិទ្ធិស្របច្បាប់របស់ជនជាតិដើមភាគតិចចំពោះការកាន់កាប់ដីធ្លីសមូហភាព និងជាលក្ខណៈបុគ្គល។ ការសិក្សាព័ត៌មានឡើងវិញបង្ហាញថា មានភាពខ្វែងគំនិតគ្នាជាមូលដ្ឋានមួយ រវាងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទរបស់រាជរដ្ឋាភិបាលកម្ពុជាដែលតម្រូវឲ្យមានការប្រើប្រាស់ដីផលិតកម្មសេដ្ឋកិច្ចបន្ថែមទៀត ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍប្រទេសជាតិ និងស្ថានភាពជាក់ស្តែង ដែលសហគមន៍ជនជាតិដើមភាគតិចជាច្រើនមានបំណងរក្សាស្ថានភាពដើមនៃដីទាំងនោះឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែ ការចុះស្រាវជ្រាវដល់មូលដ្ឋានបានផ្តល់ទស្សនៈដោយឡែកចំពោះបញ្ហាដីធ្លីទាំងនេះ។ ខណៈដែលឯកសារស្រាវជ្រាវដែលបានធ្វើឡើងជាច្រើនបង្ហាញថា បញ្ហាដីទាំងនេះគឺជាកត្តាអវិជ្ជមាន[6] ចំពោះសហគមន៍ជនជាតិដើមភាគតិច ហើយជាការពិតណាស់ សហគមន៍ជនជាតិដើមភាគតិចនានាដែលបានធ្វើបទសម្ភាសន៍នៅខេត្តរតនៈគិរីភាគច្រើនក៏បានគាំទ្រចំពោះការវិភាគនេះ ប៉ុន្តែ សហគមន៍នានានៃស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគិរីបានទទួលស្គាល់ថាដីប្រពៃណីរបស់ពួកគាត់ត្រូវបានកាត់បន្ថយ តែពួកគាត់ក៏ពេញចិត្តចំពោះដីសហគមន៍របស់ពួកគាត់ ដែលអាជ្ញាធរខេត្ត និងអាជ្ញាធរជាតិបានធ្វើការការពារសម្រាប់ការប្រើប្រាស់របស់ពួកគាត់។ វិធីសាស្ត្រនេះអាចប្រើប្រាស់ជាគំរូ ក្នុងការរក្សាតុល្យភាពប្រកបដោយជោគជ័យរវាងល័ក្ខខ័ណ្ឌនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដែលតម្រូវឲ្យមានការធ្វើប្រពលវប្បកម្មដីធ្លីជាមួយនឹងតម្រូវការព្រៃឈើរបស់ជនជាតិដើម

[6] វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, "*ជនជាតិដើមភាគតិចនៅកម្ពុជា*"; **Chakma,** "*ទស្សនវិស័យរបស់ជនជាតិដើមភាគតិច*"; **Vinding** និងការិយាល័យពលកម្មអន្តរជាតិ, "*ទស្សនៈវិស័យពីបណ្តាសហគមន៍នានានៅប្រទេសបូលីវី កម្ពុជា កាមហ្គាមេរូន កូតេម៉ាឡា និងណេប៉ាល់*"; **BirgitteFeiring,** "*ការរួមបញ្ចូលជនជាតិដើមភាគតិចទៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ៖ មគ្គុទ្ទេសអនុវត្តន៍ផ្អែកលើបទពិសោធន៍ពីប្រទេសកម្ពុជា កាមេរូន និងណេប៉ាល់*", (ហ្សឺណែវ៖ អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០៨), http://www.ilo.org/wcmsp5/groups/public/---ed_norm/---normes/documents/publication/wcms_097721.pdf .

ភាគតិច តាមរយៈមធ្យោបាយមួយដែលអាចបំពេញចិត្តគ្រប់ភាគីពាក់ព័ន្ធ និងអាចផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់ប្រទេសកម្ពុជាផងដែរ។

## ១. ការទទួលបានការអប់រំ

ក្នុងផែនការយុទ្ធសាស្ត្រចុងក្រោយបង្អស់ស្តីពីការអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បាន អះអាងជាថ្មីអំពីកាតព្វកិច្ចរបស់ខ្លួនក្រោមរដ្ឋធម្មនុញ្ញកម្ពុជា ស្របតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដើម្បីផ្តល់ជូនប្រជាជនកម្ពុជាគ្រប់រូបនូវឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំដែលមានគុណភាពល្អ ដោយមិនរើសអើងពូជសាសន៍ ភាសា ឬទីតាំងភូមិសាស្ត្រ[7]។ ផ្ទុយទៅវិញ ជនជាតិដើមភាគតិចនៅកម្ពុជា ហាក់ដូចជាមិនទទួលការអប់រំ និងលទ្ធផលសិក្សា[8] ដូចមានបង្ហាញក្នុងតារាងលេខ១ និងលេខ២ ឡើយ។ តួលេខទាំងនេះបង្ហាញថា បណ្តាខេត្តដែលមាន ប្រជាជនជនជាតិដើមភាគតិចច្រើន ដូចជានៅខេត្តរតនៈគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ [9] មានអត្រានៃការទទួលបានការអប់រំទាបជាងបណ្តាខេត្តផ្សេងទៀត ដែលមានប្រជាជនជាជនជាតិខ្មែរច្រើនលើសលប់[10]។




[7] ក្រសួងអប់រំ យុវជន និងកីឡា, "*ផែនការយុទ្ធសាស្ត្រ ២០០៩-២០១៣ របស់ក្រសួងអប់រំ*", ផែនការយុទ្ធសាស្ត្រស្តីពីការអប់រំ ២០០៩-២០១៣ (ភ្នំពេញ៖ ក្រសួងអប់រំ ឆ្នាំ២០១០), http://www.moeys.gov.kh/images/moeys/policies-and-strategies/policies-and-strategies/Education-Strategic-Plan-2009-2013/esp-2009-2013-en.pdf , ទំព័រ២.

[8] ក្រសួងអប់រំ យុវជន និងកីឡា, "*គោលនយោបាយស្តីពីការអប់រំក្រៅប្រព័ន្ធ*", ទំព័រ៣.

[9] **Chakma**, "*ទស្សនវិស័យរបស់ជនជាតិដើមភាគតិច*", ទំព័រ២៥.

[10] ក្រសួងអប់រំ យុវជន និងកីឡា, "*ស្ថិតិនិងសូចនាករនៃការអប់រំ ២០១២/២០១៣*", (ភ្នំពេញ៖ ក្រសួងអប់រំ ឆ្នាំ២០១៣), ទំព័រ៣៦.

*តារាងលេខ១៖ អត្រានៃការបញ្ចប់ការសិក្សាពីសាលារៀន*[11]




*តារាងលេខ២៖ ចំនួនសិស្សក្នុងគ្រូម្នាក់*[12]

លទ្ធផលនៃការអប់រំក្នុងកម្រិតទាបនេះ កើតឡើងដោយសារកត្តាមួយចំនួន ដូចជា របាំងភាសា ភូមិសាស្ត្រដាច់ស្រយាល និងភាពក្រីក្រ ដែលអាចធ្វើឲ្យគ្រួសារជាច្រើនមិនអាចទទួលបានការសិក្សាដែលត្រូវចំណាយប្រាក់តិចតួចបំផុតក្តី [13] ។ ផែនទីលេខ២ខាងក្រោមបង្ហាញពីអត្រាអក្ខរភាពក្នុងកម្រិតទាប ដែលបង្កឡើងដោយ អត្រាការអប់រំទាបខាងលើ។

---

[11] ផ្អែកលើទិន្នន័យមកពី៖ ឯកសារយោងដូចខាងលើ, ទំព័រ ៣៦.

[12] ផ្អែកលើទិន្នន័យមកពី៖ ឯកសារយោងដូចខាងលើ, ទំព័រ ៥៦.

[13] អង្គការ**UNICEF, Cambodia Country Kit 2011-2015, (**ភ្នំពេញ៖ អង្គការ**UNICEF**កម្ពុជា ឆ្នាំ២០១១**),**
**http://www.unicef.org/cambodia/results_for_children_18255.html**, ទំព័រ៧**.**




*ផែនទីលេខ២៖ អត្រាអក្ខរកម្ម ឆ្នាំ២០១១ នៅតាមបណ្តាខេត្តនានា*[14] ។

ក៏ប៉ុន្តែ តាមរយៈការធ្វើកំណែទម្រង់គោលនយោបាយអប់រំ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនវឌ្ឍនភាពយ៉ាងច្រើនក្នុងការដោះស្រាយបញ្ហាវិសមភាពទាំងនេះ។ វឌ្ឍនភាពនេះបានធ្វើឲ្យកម្ពុជាត្រូវបានទទួលស្គាល់ថាជាអ្នកនាំមុខក្នុងតំបន់ ក្នុងការដោះស្រាយបញ្ហាប្រឈមស្តីពីការអប់រំសម្រាប់ជនជាតិដើមភាគតិច តាមរយៈកម្មវិធីអប់រំពីរភាសារបស់ខ្លួន[15]។

---

[14] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, "*អត្រាអក្ខរភាពក្នុងឆ្នាំ២០១១*", (ភ្នំពេញ៖ អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ឆ្នាំ២០១៣), http://www.opendevelopmentcambodia.net/download/maps/atlas/en/Literacy-Rates-in-2011.jpg .

[15] **Jan Noorlander**, "*បទសម្ភាសន៍ស្តីពីបញ្ហាសិទ្ធិជនជាតិដើមភាគតិច ជាមួយអ្នកសម្របសម្រួលកម្មវិធីស្តីពីជនជាតិដើមភាគតិចដែលពុំត្រូវបានយកចិត្តទុកដាក់ របស់អង្គការ**CARE**កម្ពុជា*", ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៤; **Benson Carol**, "*ការវាយតម្លៃស្ថានភាពនៃការអប់រំពីរភាសានៅកម្ពុជា*", (ភ្នំពេញ៖ ក្រសួងអប់រំ ឆ្នាំ២០១១), http://www.careevaluations.org/Evaluations/Final%20report%20BE%20evaluation%20Benson%20FINAL%20DRAFT%2022Mar.pdf ; **Chey Chap, The In** និង **Anne Thomas**, "*ការអប់រំពីរភាសានៅកម្ពុជា*", (បទបង្ហាញ នៅក្នុងកម្មវិធីស្តីពីការអភិវឌ្ឍភាសា ការពង្រឹងភាសា និងការអប់រំជាពហុភាសានៅក្នុងសហគមន៍ជនជាតិភាគតិចនៅតំបន់អាស៊ី, បាងកក , ឆ្នាំ២០០៣), http://www.silinternational.com/asia/ldc/parallel_papers/he_chey_chap.pdf ; **Feiring**, "*ការរួមបញ្ចូលជនជាតិដើមភាគតិច*".

ការអប់រំពីរភាសា ដែលការបង្រៀនដំបូងត្រូវធ្វើឡើងជាភាសាជនជាតិ និងបន្ទាប់មកធ្វើឡើងជាភាសាខ្មែរ និងភាសាជនជាតិ[16] អាចកាត់បន្ថយគម្លាតរវាងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មិនមែនជនជាតិដើមភាគតិចនៅកម្ពុជា[17]។

មាត្រា២៤នៃច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧អនុញ្ញាតឲ្យក្រសួងអប់រំ យុវជន និងកីឡា ចេញ*ប្រកាស*ដែលអនុញ្ញាតឲ្យសាលារៀននានាអាចបង្រៀនកម្មវិធីសិក្សាមូលដ្ឋានរបស់ខ្លួនជាភាសាផ្សេងៗក្រៅពីភាសាខ្មែរបាន[18]។ លើសពីនេះ រាជរដ្ឋាភិបាលក៏ទទួលស្គាល់ភាសាចំនួន២៥ផ្សេងទៀត ដែលត្រូវបានសន្ទនាគ្នានៅក្នុងប្រទេសកម្ពុជា។ លទ្ធភាពសម្រាប់ក្រុមជនជាតិភាគតិច ជាពិសេសក្រុមជនជាតិដើមដែលមិនទំនងជាអាចនិយាយភាសាខ្មែរបានក្នុងការទទួលបានការអប់រំជាភាសាតំបន់របស់ពួកគេ ត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំថាពិតជាចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការកែលម្អស្ថានភាពសុខភាព និងសមាហរណកម្មដែលមានសុខដុមនីយកម្មទៅក្នុងសង្គមកម្ពុជា[19]។

ការផ្តល់ការអប់រំពីរភាសានេះ គឺសំខាន់ខ្លាំងណាស់ ដោយសារជាញឹកញាប់នៅក្នុងសហគមន៍ជនជាតិដើមភាគតិចមានមនុស្សតិចតួចប៉ុណ្ណោះដែលអាចនិយាយ អាន ឬសរសេរភាសាខ្មែរបាន[20]។ តាមរយៈការបង្រៀនជាភាសាជនជាតិដើមភាគតិច ធ្វើឱ្យលទ្ធផលនៃការអប់រំមានភាពប្រសើរឡើង និងលទ្ធភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ការទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ការបំពេញលក្ខខ័ណ្ឌអក្ខរកម្មចាំបាច់នានា ដើម្បីក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ[21] និងការរួមចំណែកដល់ស្ថេរភាពរបស់កម្ពុជាក៏បានធ្វើឱ្យប្រសើរឡើងផងដែរ តាមរយៈសមាហរណកម្មនយោបាយដែលប្រសើរជាងមុននៃសហគមន៍របស់ខ្លួន[22]។

## ១.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ - បញ្ហា និងដំណោះស្រាយ

នៅឆ្នាំ២០០៣ អតីតអនុរដ្ឋលេខាធិការក្រសួងអប់រំ ឯកឧត្តម ជ័យ ចាប បានទទួលស្គាល់ថា "របាំងភាសាគឺជាបញ្ហាប្រឈមបំផុតក្នុងការទទួលបានការអភិវឌ្ឍ និងការអប់រំ

---

[16] **Carol,** "*ការអប់រំពីរភាសានៅកម្ពុជា*", ទំព័រ៦.

[17] "*សិក្ខាសាលាស្តីពីការអប់រំជាពហុភាសានៅកម្ពុជា*", ដកស្រង់ព័ត៌មាននៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥, http://www.moeys.gov.kh/en/minister-page/423.html .

[18] ព្រះរាជាណាចក្រកម្ពុជា, "*ច្បាប់ស្តីពីការអប់រំ, នស/រកម/១២០៧/០៣២*", ឆ្នាំ២០០៧.

[19] "*សិក្ខាសាលាស្តីពីការអប់រំជាពហុភាសានៅកម្ពុជា*".

[20] **Carol,** "*ការអប់រំពីរភាសានៅកម្ពុជា*", ទំព័រ៦.

[21] "*សិក្ខាសាលាស្តីពីការអប់រំជាពហុភាសានៅកម្ពុជា*".

[22] **Noorlander,** "*បទសម្ភាសន៍ស្តីពីបញ្ហាសិទ្ធិជនជាតិដើមភាគតិច ជាមួយអ្នកសម្របសម្រួលកម្មវិធីស្តីពីជនជាតិដើមភាគតិចដែលពុំត្រូវបានយកចិត្តទុកដាក់ របស់អង្គការ**CARE**កម្ពុជា*".

ដោយសារមនុស្សតិចតួចប៉ុណ្ណោះនៃសហគមន៍ជនជាតិភាគតិចអាចនិយាយ[ភាសាខ្មែរ] បាន"[23]។ ភាពខុសគ្នានៃភាសានេះ មានន័យថា កិច្ចខិតខំប្រឹងប្រែងជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ការអប់រំនៅតាមសហគមន៍ជនជាតិដើមភាគតិចដាច់ស្រយាលជាច្រើន ភាគច្រើនគឺទទួលបរាជ័យ ដោយសារតែមេរៀននៅតាមសាលាទាំងនោះត្រូវបានផ្តល់តែជាភាសាខ្មែរប៉ុណ្ណោះ ដែលធ្វើឲ្យសិស្សនានាមិនអាចយល់បាន និងមិនបានយល់ពីសារៈសំខាន់ដោយផ្ទាល់នៃការសិក្សានេះចំពោះជីវិតរស់នៅរបស់ពួកគាត់[24]។

ចាប់តាំងពីឆ្នាំ២០០២មក រាជរដ្ឋាភិបាលបានបង្កើតគោលនយោបាយដើម្បីដោះស្រាយបញ្ហាទាំងនេះ តាមរយៈការបង្កើតកម្មវិធីអប់រំពីរភាសា[25]។ គោលនយោបាយនេះត្រូវបានអភិវឌ្ឍបន្ថែមទៀត នៅក្នុង*គោលការណ៍ណែនាំ ស្តីពី ការអនុវត្តកម្មវិធីអប់រំពីរភាសាសម្រាប់កុមារជនជាតិដើមភាគតិច នៅបណ្តាខេត្តតំបន់ភ្នំ* ដែលបានចេញនៅឆ្នាំ២០១០ ដោយអតីតរដ្ឋមន្ត្រីក្រសួងអប់រំ ឯកឧត្តម អ៊ឹម សិទ្ធី[26]។ គោលនយោបាយនេះបានពង្រីកតាមរយៈគម្រោងសាកល្បងមួយរបស់អង្គការឃែរ**(CARE)** ដែលជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ គម្រោងដើមរបស់អង្គការឃែរ**(CARE)** គឺជាគម្រោងអប់រំកុមារតំបន់ភ្នំ ដែលសាកល្បងទៅលើសាលារៀនសហគមន៍ចំនួន០៦ នៅក្នុងខេត្តរតនៈគិរី[27]។

សាលារៀនទាំងនេះត្រូវបានដំណើរការដោយសហគមន៍មូលដ្ឋាន ហើយសហគមន៍មូលដ្ឋានជាអ្នកសម្របសម្រួលកាលវិភាគ និងមុខវិជ្ជាសិក្សាឲ្យស្របទៅតាមតម្រូវការក្នុងមូលដ្ឋាន ជាងនេះទៅទៀតសហគមន៍ក៏ជាអ្នកផ្តល់បុគ្គលិកបង្រៀនដែលមានប្រភពមកពីមូលដ្ឋានស្រាប់ និងអាចបង្រៀនជាពីរភាសាផងដែរ[28]។ គម្រោងនេះបានកំណត់បញ្ហាប្រឈមសំខាន់ៗចំនួន០៤ ដើម្បីលើកកម្ពស់វិស័យអប់រំនៅក្នុងសហគមន៍ជនជាតិភាគតិចដែលមានភូមិសាស្ត្រដាច់ស្រយាល ដូចខាងក្រោម៖

១**)** កង្វះហេដ្ឋារចនាសម្ព័ន្ធសមស្រប

២**)** កង្វះការគាំទ្រពីមូលដ្ឋានចំពោះការអប់រំ

---

[23] **Chap, In** និង **Thomas,** "*ការអប់រំពីរភាសានៅកម្ពុជា*", ទំព័រ១.

[24] ដូចឯកសារយោងខាងលើ.

[25] ក្រសួងអប់រំ យុវជន និងកីឡា, "*គោលនយោបាយស្តីពីការអប់រំក្រៅប្រព័ន្ធ*", (ភ្នំពេញ៖ ក្រសួងអប់រំ ឆ្នាំ២០០២**)**, ទំព័រ ៦ និងទំព័រ៣៣-៤៤.

[26] **Carol,** "*ការអប់រំពីរភាសានៅកម្ពុជា*", ទំព័រ៤-៦.

[27] ដូចឯកសារយោងខាងលើ.

[28] **Jorn Middleborg,** "*គម្រោងអប់រំកុមារតំបន់ភ្នំ៖ គម្រោងសាកល្បងស្តីពីការអប់រំពីរភាសានៅកម្ពុជា*", (បាងកក៖ អង្គការ **UNESCO** ឆ្នាំ២០០៥**)**, ទំព័រ ១-៣.

៣) កង្វះគ្រូបង្រៀនដែលទទួលការបណ្តុះបណ្តាល និងមានប្រភពមកពីសហគមន៍ និង

៤) មានសម្ភារបង្រៀនជាភាសាមូលដ្ឋានសមស្របតិចតួច ឬគ្មានតែម្តង[29]។

បញ្ហាប្រឈមពីរដំបូងគេ ភាគច្រើនត្រូវបានដោះស្រាយតាមរយៈវិធីសាស្ត្រផ្អែកលើសហគមន៍របស់គម្រោង។ មូលហេតុនៃការធ្វើបែបនេះគឺដោយសារមេភូមិដែលបានដំណើរការសាលារៀនទាំងនេះ ជាអ្នកដែលទទួលការគោរព និងមានឥទ្ធិពលច្រើននៅក្នុងភូមិ ហេតុនេះសហគមន៍នានាមានឆន្ទៈក្នុងការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ [30]។ ស្រដៀងគ្នានេះ មេភូមិទាំងនោះអាចរៀបចំកម្មវិធីសិក្សាស្របតាមតម្រូវការមូលដ្ឋាន និងអាចជំរុញឲ្យមានការគាំទ្រច្រើនចំពោះការអប់រំនៅក្នុងសហគមន៍របស់ខ្លួន។ ជាមួយគ្នានេះ បញ្ហាប្រឈមទី៣ ត្រូវបានដោះស្រាយតាមរយៈការផ្តល់ការបណ្តុះបណ្តាលសកម្មដល់គ្រូបង្រៀនមានប្រភពមកពីមូលដ្ឋាន និងបន្ទាប់មកផ្តល់ការបណ្តុះបណ្តាលបន្តដល់គ្រូបង្រៀនទាំងនោះនៅពេលពួកគាត់អនុវត្តការងារបង្រៀន។ ប្រការនេះជាផ្នែកមួយនៃវិធីសាស្ត្ររយៈពេលវែង ក្នុងការបង្កើតសាលាបណ្តុះបណ្តាលគ្រូបង្រៀនប្រចាំតំបន់ ដែលផ្តោតលើការបណ្តុះបណ្តាលគ្រូបង្រៀនពីរភាសា [31]។ បញ្ហាប្រឈមទី៤ ត្រូវបានដោះស្រាយតាមរយៈការបង្កើតអក្សរ ដោយផ្អែកលើអក្សរសាស្ត្រខ្មែរ សម្រាប់ភាសាជនជាតិដើមភាគតិចដែលខ្វះខាតប្រព័ន្ធនៃការសរសេរ[32]។ ប្រការនេះត្រូវបានអនុវត្តដោយជោគជ័យ ដោយគណៈកម្មាធិការពិសេសរបស់ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអ្នកបោះពុម្ពផ្សាយនៃគេហទំព័រភាសាពិភពលោក **(enthonolgue) -** ប្រភពឯកសារយោងភាសាអន្តរជាតិនាំមុខគេបង្អស់ [33] ដែលបានសម្រួលអក្សរសាស្ត្រខ្មែរទៅតាមតម្រូវការនៃភាសាជនជាតិដើមភាគតិចនានា[34]។ គំរូនេះបានប៉ាន់ប្រមាណថា ៨០**%**នៃការបង្រៀននឹងត្រូវធ្វើឡើងជាភាសាតំបន់ជនជាតិនៅថ្នាក់ទី១ និងផ្លាស់ប្តូរបន្តិចម្តងៗដោយការបង្រៀន១០០**%** នឹងត្រូវធ្វើឡើងជាភាសាខ្មែរនៅត្រឹមថ្នាក់ទី៤ [35]។

បច្ចុប្បន្ន សាលារៀនពីរភាសាបានដាក់ឲ្យដំណើរការនៅខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តរតនៈគិរី និងខេត្តស្ទឹងត្រែង ដោយប្រើប្រាស់ភាសាជនជាតិចំនួន ០៥ ផ្សេង

[29] ដូចឯកសារយោងខាងលើ ទំព័រ១១-១៤.

[30] ដូចឯកសារយោងខាងលើ ទំព័រ២.

[31] ដូចឯកសារយោងខាងលើ ទំព័រ១៥.

[32] ដូចឯកសារយោងខាងលើ.

[33] **Ethnologue,** ដែលបោះពុម្ពផ្សាយដោយស្ថាប័ន**SIL International,** គឺជាស្តង់ដានៃឯកសារយោងផ្នែកសិក្សាធិការសម្រាប់ភាសាផ្សេងៗ.

[34] **Middleborg,** *"គម្រោងអប់រំកុមារតំបន់ភ្នំ៖ គម្រោងសាកល្បងស្តីពីការអប់រំពីរភាសានៅកម្ពុជា"*, ទំព័រ៣.

[35] ដូចឯកសារយោងខាងលើ ទំព័រ២៧.

គ្នា[36]។ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានជំនួយបច្ចេកទេសពីអង្គការឃែ **(CARE)** កម្ពុជា បានដាក់ឲ្យដំណើរការសាលារៀនពីរភាសាចំនួន៥២ សាលា ដោយមានគ្រូបង្រៀនជាជនជាតិភាគតិចចំនួន ២០៧នាក់ ដែលកំពុងបង្រៀនសិស្សប្រហែល៤០០០នាក់ នាពេលបច្ចុប្បន្ន[37]។ ជាងនេះទៅទៀត បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាក៏កំពុងស្ថិតក្នុងដំណើរការនៃការអភិវឌ្ឍផែនការ ដែលសំដៅបង្កើនចំនួនខេត្តប្រើប្រាស់ប្រព័ន្ធអប់រំពីរភាសា និងបង្កើនចំនួនភាសាសម្រាប់ប្រើប្រាស់ក្នុងការអប់រំពីរភាសានេះផងដែរ[38]។

## ១.២. ការស្រាវជ្រាវនៅមូលដ្ឋាន

ការចុះស្រាវជ្រាវដល់មូលដ្ឋានដែលបានធ្វើឡើង ក៏បញ្ជាក់ជាថ្មីនូវបញ្ហាដូចគ្នាដែលបានលើកឡើងនៅក្នុងការសិក្សាខាងលើ៖ បញ្ហាភាសានៅតែជាការប្រឈមដ៏សំខាន់មួយក្នុងការផ្តល់ការអប់រំសម្រាប់សហគមន៍ជនជាតិដើមភាគតិចនានា។ នៅក្នុងសហគមន៍ទាំង ០៧ ដែលបានចុះទៅដល់ ភាសាជនជាតិដើមចំនួន៤(ព្នង កាចក ចារ៉ាយ និងគ្រឹង) គឺជាភាសាចាំបាច់ដំបូងបង្អស់នៃសហគមន៍ទាំងនេះ។ ឃុំប៊ូស្រានៃស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគិរីវិញ គឺមានភាពលាយលំគ្នារវាងអ្នកដើមកំណើតនិយាយភាសាខ្មែរ និងអ្នកដើមកំណើតនិយាយភាសាព្នង [39] ។ សហគមន៍ដែលមានប្រជាជនលាយលំគ្នារវាងអ្នកដើមកំណើតខ្មែរ និងអ្នកដើមកំណើតជនជាតិដើមភាគតិចបែបនេះ អាចតម្រូវឲ្យមានប្រព័ន្ធនៃការអប់រំជាភាសាខ្មែរផង និងប្រព័ន្ធនៃការអប់រំជាពីរភាសាផង ដើម្បីអនុញ្ញាតឲ្យប្រជាជនគ្រប់រូបមានឱកាសទទួលបានការអប់រំ។

ផ្ទុយទៅវិញ កង្វះខាតអាគារសិក្សា និងគ្រូបង្រៀនក៏ត្រូវបានលើកឡើងថាជាបញ្ហារួមនៃការអប់រំនៅក្នុងសហគមន៍ទាំងនេះផងដែរ។ ទោះបីជាមានសហគមន៍ចំនួន ០៦ ក្នុងចំណោមសហគមន៍ទាំង ០៧ អាចចូលរៀននៅសាលាបឋមសិក្សាក៏ដោយ ក៏នៅមានសហគមន៍មួយបានឲ្យដឹងថាសហគមន៍របស់ខ្លួនពុំមានសាលារៀនទាល់តែសោះ ឬមានសាលារៀនដែលស្ថិតនៅឆ្ងាយពីសហគមន៍ ហើយសហគមន៍ពីរផ្សេងទៀតបានត្អូញត្អែរអំពីកង្វះគ្រូបង្រៀន ដូចជាករណី ការទទួលបានតែបុគ្គលិកកិច្ចសន្យារយៈពេលខ្លីដែលពុំមានឆន្ទៈបំពេញការងារ ជំនួសឲ្យគ្រូបង្រៀនដែលមកពីក្រសួងអប់រំ យុវជន និងកីឡា ឬពុំ

---

[36] **Carol,** “*ការអប់រំពីរភាសានៅកម្ពុជា*”; “*សិក្ខាសាលាស្តីពីការអប់រំជាពហុភាសានៅកម្ពុជា*”.

[37] **Noorlander,** “*បទសម្ភាសន៍ស្តីពីបញ្ហាសិទ្ធិជនជាតិដើមភាគតិច ជាមួយអ្នកសម្របសម្រួលកម្មវិធីស្តីពីជនជាតិដើមភាគតិចដែលពុំត្រូវបានយកចិត្តទុកដាក់ របស់អង្គការ**CARE**កម្ពុជា*”.

[38] ដូចឯកសារយោងខាងលើ

[39] ថ្នាក់ដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរីនិងមណ្ឌលគិរី, ការចុះស្រាវជ្រាវដល់មូលដ្ឋាន ដោយធ្វើបទសម្ភាសន៍ជាមួយថ្នាក់ដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរីនិងមណ្ឌលគិរី, ធ្វើបទសម្ភាសន៍ដោយ **Sebastian Abjorensen** បកប្រែដោយ **San Sokprapey,** ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩.

មានគ្រូបង្រៀនគ្រប់គ្រាន់តែម្តង។ សហាគមន៍ពីរទៀតបានលើកឡើងថា កុមារជាច្រើននៅក្នុងសហាគមន៍ពុំបានយល់ដឹងអំពីសារៈសំខាន់នៃការសិក្សា ប៉ុន្តែសហាគមន៍ទាំងនេះបានកោតសរសើរចំពោះអាជ្ញាធរខេត្ត ដែលតែងតែមកទស្សនកិច្ចសហាគមន៍ ដើម្បីពន្យល់កុមារទាំងនោះឲ្យយល់ដឹងអំពីសារៈសំខាន់នៃការសិក្សា។ ភូមិមួយទៀតបានលើកឡើងថា នៅក្នុងសហាគមន៍របស់ពួកគាត់កុមារីចូលរៀននៅសាលាបឋមសិក្សាច្រើនជាងកុមារា ដោយសារកុមារាត្រូវបានរំពឹងថានឹងត្រូវចាប់ផ្តើមធ្វើការងារទាំងវ័យក្មេង[40]។

សហាគមន៍ចំនួន ០៤ នៃសហាគមន៍ទាំង ០៧ បាននិយាយថា ពួកគេមានឱកាសគ្រប់គ្រាន់ក្នុងការចូលរៀននៅមធ្យមសិក្សា ទាំងសាលារៀនដែលនៅជិតសហាគមន៍ ឬតាមរយៈការផ្តល់អាហារូបករណ៍ដល់សិស្សដោយអាជ្ញាធរខេត្តសម្រាប់សិស្សសិក្សានៅមធ្យមសិក្សាដែលមានទីតាំងឆ្ងាយពីសហាគមន៍របស់ខ្លួន។ ចំណែកឯ សហាគមន៍ ០៣ ផ្សេងទៀតបានលើកឡើងថា ពួកគេមិនបានដឹងអំពីកម្មវិធីអាហារូបករណ៍នេះទេ ព្រមទាំងបន្ថែមទៀតថា នៅក្នុងសហាគមន៍របស់ពួកគេពុំមាននរណាម្នាក់អាចមានឱកាសទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សានោះទេ[41]។

មានសិស្សប្រហែលជា ០៣ នាក់ប៉ុណ្ណោះ មកពីសហាគមន៍ដែលបានស្ទង់មតិ កំពុងបន្តការសិក្សារបស់ពួកគេនៅសកលវិទ្យាល័យនៅទីក្រុងភ្នំពេញ[42]។

## ២. ការទទួលបានសេវាថែទាំសុខភាព

ប្រជាជនជនជាតិដើមភាគតិចនៅកម្ពុជាភាគច្រើន មានស្ថានភាពសុខភាពទន់ខ្សោយជាងប្រជាជន កម្ពុជាទូទៅ[43]។ ហេតុនេះ ក្នុងចំណោមខេត្តទាំង ០៣ ដែលគណៈកម្មការទី១នៃព្រឹទ្ធសភា នឹងធ្វើទស្សនកិច្ច គឺខេត្តចំនួន០២ គឺខេត្តក្រចេះ និងខេត្តមណ្ឌលគិរី មានចំនួនប្រជាជនជនជាតិដើមភាគតិចយ៉ាងច្រើន និងមានស្ថានភាពសុខភាពមិនល្អដូចគ្នាផងដែរ[44]។ ផ្ទុយទៅវិញ ខេត្តកំពង់ចាមពុំមានចំនួនប្រជាជនជនជាតិដើមភាគតិចច្រើននោះទេ ហើយក៏មានស្ថានភាពសុខភាពដូចគ្នាទៅនឹងប្រជាជនមធ្យមនៅទូទាំងប្រទេស [45] ។

---

[40] ដូចឯកសារយោងខាងលើ

[41] ដូចឯកសារយោងខាងលើ.

[42] ដូចឯកសារយោងខាងលើ.

[43] **Corinna Heineke** និង **Sara Edwards** វិសមភាពសុខភាពរបស់ជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ - ការប្រែប្រួលតាមរយៈក្របខ័ណ្ឌអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥ - ពិភពលោកដែលយើងចង់: ដំណោះស្រាយវិសមភាព (ទីក្រុងហ្សឺណែវ: ក្រុមអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ឆ្នាំ២០១២)

[44] ដូចឯកសារយោងខាងលើ.

[45] អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច, "ជនជាតិដើមភាគតិចនៅកម្ពុជា", ឆ្នាំ២០១០, http://www.icso.org.kh/indigenous-people/indigenous-people-in-cambodia/ , ទំព័រ៦.

និន្នាការនៃស្ថានភាពសុខភាពទន់ខ្សោយរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជានេះ គឺបង្ហាញភស្តុតាងកាន់តែច្បាស់ថែមទៀតនៅក្នុងខេត្តរតនៈគិរី និងស្ទឹងត្រែង ដែលជាខេត្តដែលមានចំនួនប្រជាជនជនជាតិដើមភាគតិចច្រើន និងត្រូវបានរាយការណ៍ថា មានសូចនាករសុខភាពទាបជាងមធ្យមភាគទូទាំងប្រទេសច្រើន [46] ។ លំនាំស្ថានភាពនេះ មានបង្ហាញនៅក្នុងផែនទីលេខ៣ខាងក្រោម ដែលបង្ហាញពីការប្រៀបធៀបអត្រាមរណភាពរបស់កុមារនៅបណ្តាខេត្តនានា ហើយក៏អាចប្រើប្រាស់ជាសូចនាករទូទៅមួយចំពោះស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋផងដែរ[47]។ នេះជាការគួរឲ្យកត់សម្គាល់ផងដែរថា តួរលេខរបស់ក្រសួងសុខាភិបាលដែលបានប្រើប្រាស់នៅក្នុងឯកសារនេះ ពុំបានញែកដាច់ពីគ្នារវាងខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរីនៅក្នុងបញ្ហាភាគច្រើននោះទេ ដោយហេតុនេះហើយទើបខេត្តទាំងពីរត្រូវបានរួមបញ្ចូលគ្នានៅក្នុងការវិភាគខាងក្រោម។ អត្រាមរណភាពទាំងនេះពិតជាមានសារៈសំខាន់ណាស់ ដោយសារអត្រានេះត្រូវបានប្រើប្រាស់ជាសូចនាកររួមមួយដែលបង្ហាញអំពីស្ថានភាពនៃប្រព័ន្ធសុខាភិបាល និងស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋដែលប្រើប្រាស់ប្រព័ន្ធសុខាភិបាលនេះ[48]។




[46] **Heineke and Edwards,** វិសមភាពសុខភាពរបស់ជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ - ការប្រែប្រួលតាមរយៈក្របខ័ណ្ឌអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥

[47] ក្រសួងសុខាភិបាល, "ផែនការយុទ្ធសាស្ត្រផ្នែកសុខាភិបាល ២០០៨-២០១៥", (ភ្នំពេញ៖ ក្រសួងសុខាភិបាល ឆ្នាំ ២០០៨), ទំព័រ១០.

[48] ដូចឯកសារយោងខាងលើ. ទំព័រ១០.

*ផែនទីលេខ៣៖ អត្រាមរណភាពរបស់កុមារអាយុក្រោម៥ ក្នុងចំណោមកុមារ១០០០នាក់* [49]

កម្ពុជាមានអត្រាមរណភាពរបស់ទារកជាមធ្យម ២៧ នាក់ ក្នុងចំណោមការបង្កកំណើតទារក ១០០០ នាក់ និង អត្រាមរណភាពរបស់ទារកក្រោយពេលប្រសូត្រមាន ១៨ នាក់ ក្នុងចំណោមការបង្កកំណើតទារក ១០០០ នាក់ រីឯអត្រាមរណភាពរបស់ទារក (ទារកអាយុក្រោម១ឆ្នាំ) ៤៥នាក់ក្នុងចំណោមការបង្កកំណើតទារក ១០០០ នាក់។ ជាមធ្យមក្នុងចំណោម កុមារ ១០០០ នាក់ កុមារ ៥៤ នាក់នឹងស្លាប់មុនពេលដែលពួកគេឈានដល់អាយុ ៥ ឆ្នាំ[50]។

តាមរយៈការប្រៀបធៀប ខេត្តនីមួយៗដែលបានចោទសួរមានពិន្ទុទាបខ្លាំងបើធៀបនឹងមធ្យមភាគទូទាំងប្រទេសសម្រាប់សូចនាករនីមួយៗ ដូចបានបង្ហាញនៅក្នុងតារាងលេខ ៣ ខាងក្រោម។ ក្នុងចំណោមសូចនាករទាំងនេះ អត្រាមរណភាពរបស់កុមារអាយុក្រោម ៥ ឆ្នាំនៅខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី គឺមានលក្ខណៈគួរឲ្យកត់សម្គាល់បំផុត ដោយសារវាមានតួរលេខស្ទើតែទ្វេដងបើធៀបនឹងមធ្យមភាគទូទាំងប្រទេស គឺក្នុងចំណោមកុមារ ១០០០ នាក់ នៅស្ទឹងត្រែងស្លាប់ ១១៨ នាក់ នៅមណ្ឌលគិរីស្លាប់ ១០៦ នាក់ និងនៅរតនៈគិរីស្លាប់ ១០៦ នាក់[51]។




[49] ផែនទីដែលចងក្រងឡើងដោយប្រើប្រាស់ទិន្នន័យមកពី៖ វិទ្យាស្ថានជាតិស្ថិតិ និងអគ្គនាយកដ្ឋានសុខាភិបាល, "*ការស្ទង់មតិស្តីពីសុខភាពនិងប្រជាសាស្ត្រ ឆ្នាំ២០១០*".

[50] វិទ្យាស្ថានជាតិស្ថិតិ និងអគ្គនាយកដ្ឋានសុខាភិបាល, "*ការស្ទង់មតិស្តីពីសុខភាពនិងប្រជាសាស្ត្ររបស់កម្ពុជា ឆ្នាំ២០១០*", (ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១១), ទំព័រ១១៤.

[51] ដូចឯកសារយោងខាងលើ ទំព័រ១១៦.

*តារាងលេខ៣៖ អត្រាមរណភាពក្នុងចំណោមកុមារ១០០០នាក់ នៅតាមបណ្តាខេត្ត*[52]

## ២.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ-បញ្ហា និងដំណោះស្រាយ

ការសិក្សាព័ត៌មានឡើងវិញ និងការស្រាវជ្រាវនៅមូលដ្ឋាន បានរកឃើញឧបសគ្គជាក់លាក់ធំៗបំផុតមួយចំនួនដូចខាងក្រោម ដែលរារាំងការទទួលបានការថែទាំសុខភាព៖

១.ថវិកា-ដោយសារតែសហគមន៍ជនជាតិដើមភាគតិចភាគច្រើន នៅតែពឹងផ្អែកទាំងស្រុងលើការធ្វើកសិកម្មដើម្បីចិញ្ចឹមជីវិត ដូច្នេះពួកគាត់គ្មានតម្រូវការចាំបាច់ក្នុងការរកប្រាក់ ឬមានប្រាក់ច្រើននោះទេ។ ប៉ុន្តែ បើទោះបីជាការចំណាយប្រាក់មានចំនួនតិចតួចយ៉ាងណាក្តី ក៏ជាទូទៅការថែទាំសុខភាព របស់ប្រជាជនកម្ពុជានៅតែជាបន្ទុកដ៏ធំមួយ ដែលក្រុមគ្រួសារជនជាតិដើមភាគតិចភាគច្រើនគ្មានលទ្ធភាពធ្វើបាន។

២.មធ្យោបាយធ្វើដំណើរ-បញ្ហានេះក៏ពាក់ព័ន្ធនឹងថវិកាដែរ ដោយសារគ្រួសារភាគច្រើនដែលគ្មានម៉ូតូ ពុំមានលទ្ធភាពចំណាយចាំបាច់សម្រាប់ធ្វើដំណើរទៅកាន់មន្ទីរព្យាបាល ដែលស្ថិតនៅភូមិជិតខាង។

៣.ការផ្តល់សេវាសុខភាពមិនទាន់បានល្អ-កង្វះបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាល និងជានិច្ចកាល ថ្នាំផុតកាលបរិច្ឆេទកំណត់ធ្វើឲ្យការផ្តល់សេវាសុខភាពនៅមានគុណភាពទាបខ្លាំងនៅឡើយ។

៤.ភាសា-ជនជាតិដើមភាគតិចជាច្រើន ជាពិសេសស្ត្រី មិនចេះនិយាយភាសាខ្មែរទេ។ បញ្ហានេះក៏បង្កជាឧបសគ្គមួយផ្សេងទៀតដែរក្នុងការទទួលបានសេវាថែទាំសុខភាព ជាពិសេសនៅពេលមិត្តភក្តិ ឬសាច់ញាតិរបស់ពួកគាត់ជាប់រវល់មិនអាចជួយបកប្រែភាសាឲ្យពួកគាត់បាន។

៥.ជំនឿប្រពៃណី-ជំនឿប្រពៃណីទាក់ទងនឹងជំងឺនានា ដែលពួកគាត់យល់ថាបណ្តាលមកពីព្រលឹង ឬមន្តអាគមន៍ផ្សេងៗ នៅតែចាក់ឫសយ៉ាងជ្រៅក្នុងសហគមន៍ជនជាតិដើមភាគតិច ហើយការព្យាបាលតាមបែបប្រពៃណីគឺចំណាយអស់តិចជាងការផ្តល់សេវាសុខភាពតាមបែបសម័យទំនើប។ កត្តានេះហើយដែលធ្វើឲ្យជនជាតិដើម

[52] ដូចឯកសារយោងខាងលើ ទំព័រ ១១៤

ភាគតិចមកស្វែងរកសេវាសុខភាពយឺតយ៉ាវ និងអាចបណ្តាលឲ្យជំងឺនោះ កាន់តែធ្ងន់ធ្ងរទៅ ជាពិសេសក្នុងករណីស្ថានភាពជំងឺដែលត្រូវការសង្គ្រោះបន្ទាន់[53]។

កត្តាទាំងនេះបង្ហាញពីសុខភាពមិនល្អរបស់សហគមន៍ជនជាតិដើមភាគតិច គួបផ្សំការរស់នៅតាមតំបន់ដាច់ស្រយាល ខ្វះខាតថវិកា ឧបសគ្គខាងភាសា និងជំនឿជាប្រពៃណីរបស់ពួកគាត់ផង[54]។

## ២.២. ការស្រាវជ្រាវនៅមូលដ្ឋាន

ការស្រាវជ្រាវនៅមូលដ្ឋានបានបញ្ជាក់យ៉ាងច្បាស់នូវការស្រាវជ្រាវដែលមានស្រាប់ ដោយបានបង្ហាញថា ការទទួលបានសេវាថែទាំសុខភាពនៅមានភាពខ្វះខាតនៅឡើយ ទោះបីជាមានការរីកចម្រើនខ្លាំងអំឡុងពេល១០ឆ្នាំចុងក្រោយនេះក្តី[55]។

អ្នកចូលរួមឆ្លើយសំណួរចំនួនប្រាំនាក់ក្នុងចំណោមប្រាំពីរនាក់ឆ្លើយថា សហគមន៍របស់ពួកគាត់មានមន្ទីរព្យាបាលបម្រើសេវាសុខភាពបានគ្រប់គ្រាន់ រីឯសហគមន៍ពីរទៀតស្ថិតនៅឆ្ងាយពីមន្ទីរព្យាបាល។ ទិដ្ឋភាពជារួមគឺថា ស្រ្តីចូលចិត្តធ្វើដំណើរទៅកាន់មន្ទីរពេទ្យខេត្តនៅពេលសម្រាលកូន ដោយសារតែនៅទីនោះមានបុគ្គលិក និងគ្រឿងបរិក្ខារពេទ្យល្អជាងមន្ទីរព្យាបាលនៅមូលដ្ឋាន[56]។

គ្រប់សហគមន៍ទាំងអស់ដែលបានធ្វើបទសម្ភាសន៍បានឆ្លើយថា ស្ថានភាពសុខភាព និងអនាម័យរបស់ ពួកគាត់មានភាពល្អប្រសើរជាងមុនក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយនេះ ប៉ុន្តែក៏មានសហគមន៍ចំនួនពីរក្នុងចំណោមសហគមន៍ទាំងអស់នេះ បានកោតសរសើរចំពោះការបណ្តុះបណ្តាលស្តីពីសុខភាពដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងអ

---

[53] សុខភាពគ្មានព្រំដែន-*ការបំពេញការងាររបស់ស្រ្តីជនជាតិដើមភាគតិចឆ្ពោះទៅការលើកកម្ពស់សុខភាពមាតា*(ខេត្តរតនគិរី៖ សុខភាពគ្មានព្រំដែនឆ្នាំ២០០៦) **Noorlander** បទសម្ភាសន៍ស្តីពីបញ្ហាសិទ្ធិជនជាតិដើមភាគតិចជាមួយ និងអ្នកសម្របសម្រួលកម្មវិធីរបស់អង្គការ **CARE Cambodia** ស្តីពីក្រុមជនជាតិដើមភាគតិចតូចៗ អង្គការពលកម្មអន្តរជាតិ **(ILO)** និងមជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ ជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធ និង*យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា* (ទីក្រុងហ្សឺណែវ៖ អង្គការ **ILO** ឆ្នាំ២០០៥) មេដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី និងមណ្ឌលគិរី -ការស្រាវជ្រាវនៅមូលដ្ឋាន ការធ្វើបទសម្ភាសន៍ជាមួយមេដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនគិរី និងមណ្ឌលគិរី។

[54] សុខភាពគ្មានព្រំដែន-ការងារស្រ្តីជនជាតិដើមភាគតិចឆ្ពោះទៅការលើកកម្ពស់សុខុភាពមាតា

[55] មេដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី និងមណ្ឌលគិរី -ការស្រាវជ្រាវនៅមូលដ្ឋាន-បទសម្ភាសន៍ជាមួយមេដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិ រី។

[56] ដូចឯកសារយោងខាងលើ

ណ្តុងទឹកស្អាតដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនកាប់ឈើ មានលក្ខណៈល្អប្រសើរជាងសេវាដែលផ្តល់ដោយរដ្ឋាភិបាល[57]។

បើទោះបីជាមានការរីកចម្រើនទាំងនេះក្តី ក៏បញ្ហាសុខភាពជាមូលដ្ឋាននៅតែកើតមានក្នុងសហគមន៍ជនជាតិដើមភាគតិចទាំងនេះ។ ភូមិចំនួនបីបានបញ្ជាក់ថា បញ្ហាធំបំផុតរបស់ពួកគាត់ គឺទាក់ទងទៅនឹងសុខភាពមាតា ដោយសារតែអ្នកភូមិរបស់ពួកគាត់គ្មានការយល់ដឹងអំពីសារៈសំខាន់នៃការថៃទាំសុខភាពក្នុងអំឡុងពេលមានផ្ទៃពោះ ឬនៅពេលមានជំងឺ ហើយពឹងផ្អែកតែលើការព្យាបាលដោយឱសថបុរាណ។ សហគមន៍មួយ បានបញ្ជាក់ថា បញ្ហាសុខភាពធំបំផុតរបស់ពួកគាត់គឺជំងឺគ្រុនចាញ់ រីឯសហគមន៍មួយផ្សេងទៀតបានឆ្លើយថាជំងឺរបេង និងសហគមន៍ចំនួនបីទៀតបានបញ្ជាក់ថា បញ្ហាប្រឈមធំបំផុតរបស់ខ្លួន គឺទាំងជំងឺគ្រុនចាញ់ និងជំងឺរបេង[58]។

## ៣. ការចូលរួមនយោបាយរបស់ជនជាតិដើមភាគតិចក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់

ការចូលរួមក្នុងនយោបាយ គឺមានសារៈសំខាន់សម្រាប់សហគមន៍ជនជាតិដើមភាគតិច ដើម្បីឱ្យពួកគាត់អាចមានមតិយោបល់លើគោលនយោបាយរបស់រដ្ឋាភិបាលដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគាត់ និងក៏ដើម្បីជំរុញឱ្យរាជរដ្ឋាភិបាលអនុវត្តគោលនយោបាយឲ្យបានកាន់តែល្អប្រសើរឡើងនៅតាមតំបន់ជនជាតិដើមភាគតិចដែលត្រូវការអ្នកជំនាញក្នុងស្រុកផងដែរ[59] ។

ទោះបីជាមានការកើនឡើងចំនួនសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ជាជនជាតិដើមភាគតិចក្តី ក៏តម្រូវឲ្យមានការចូលរួមឲ្យបានច្រើនពីជនជាតិដើមភាគតិចក្នុងការនិយាយ និងអានភាសាខ្មែរ ជាពិសេសស្ត្រីដែលមានអត្រាអក្ខរកម្មទាប[60]។ ស្រដៀងគ្នានេះដែរ ផ្អែកតាមការសិក្សាអំពីការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១២ បានរកឃើញថាឧបសគ្គខាងភាសា និង

---

[57] ដូចឯកសារយោងខាងលើ

[58] ដូចឯកសារយោងខាងលើ

[59] អង្គការពលកម្មអន្តរជាតិ **(ILO)** និងមជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ ជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ ទំព័រ ៥០

[60] **Noorlander,** "បទសម្ភាសន៍ស្តីពីបញ្ហាសិទ្ធិជនជាតិដើមភាគតិច ជាមួយអ្នកសម្របសម្រួលកម្មវិធីស្តីពីជនជាតិដើមភាគតិចដែលពុំត្រូវបានយកចិត្តទុកដាក់របស់អង្គការ **CARE Cambodia** ".

ការខ្វះការអប់រំ ជាមូលហេតុបណ្តាលឲ្យជនជាតិដើមភាគតិចជាច្រើនមិនអាចទៅបោះឆ្នោតបាន ឬមិនបានចូលរួមនៅក្នុងដំណើរការបោះឆ្នោតតែម្តង[61]។

ជាទូទៅ ស្ត្រីគឺមានភាពជាតំណាងតិចតួចនៅឡើយនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលមានចំនួនប្រមាណ២០ភាគរយប៉ុណ្ណោះនៃសមាជិកក្រុមប្រឹក្សាទាំងអស់នៅក្នុងបណ្តាខេត្តដែលបានលើកឡើងក្នុងរបាយការណ៍នេះ[62]។

## ៣.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ -បញ្ហា និងដំណោះស្រាយ

ការលើកកម្ពស់ការចូលរួមរបស់ជនជាតិដើមភាគតិចនៅក្នុងនយោបាយនៅមូលដ្ឋាន គឺជាគោលបំណងដ៏សំខាន់មួយនៃកម្មវិធីវិមជ្ឈការ និងសហវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការណ៍នេះ ត្រូវបាន អនុលោមតាមការធ្វើសេចក្តីសម្រេចនយោបាយដែលផ្ទេរពីភ្នំពេញទៅថ្នាក់ឃុំ-សង្កាត់។ ផ្នែកមួយនៃគោលនយោបាយនេះ គឺពាក់ព័ន្ធនឹងការលើកទឹកចិត្តការចូលរួមឲ្យកាន់តែច្រើនពីសំណាក់ជនជាតិដើមភាគតិចនៅក្នុងនយោបាយឃុំ-សង្កាត់ ជាកម្រិតមួយពាក់ព័ន្ធនឹងបញ្ហានានាដែលជះឥទ្ធិពលដល់សហគមន៍ដោយផ្ទាល់បំផុត។ វិធីសាស្ត្រនេះអាចផ្តល់ផលប្រយោជន៍ដល់កម្ពុជាទាំងមូល ក៏ដូចជាជនជាតិដើមភាគតិច ជាពិសេសសម្រាប់ហេតុផលដ៏សំខាន់ពីរយ៉ាង៖

១-វិធីសាស្ត្រនេះនឹងពង្រឹង និងពង្រីកប្រជាធិបតេយ្យនៅមូលដ្ឋាន និងសមត្ថភាពគ្រប់គ្រង

២-វិធីសាស្ត្រនេះនឹងជួយឲ្យជនជាតិដើមភាគតិចអាចចូលរួមបង្កើត និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍នានា និងគ្រប់គ្រងធនធាន ដែលអាចលើកកម្ពស់ផលប្រយោជន៍ទាំងសហគមន៍ជនជាតិដើមភាគតិច និងប្រទេសកម្ពុជាទាំងមូល[63]។

អាទិភាពនយោបាយដ៏សំខាន់បំផុតសម្រាប់ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា គឺសិទ្ធិដីធ្លី និងការទទួលបានកម្មសិទ្ធិដីធ្លីសមូហភាពរបស់ពួកគាត់ ដោយមានការទទួលស្គាល់ និងការការពារពីការទន្ទ្រាន[64]។ បញ្ហាបន្ទាប់បន្សំ គឺបញ្ហាលំបាកក្នុងការទទួលបាន

---

[61] គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(ខុមហ្វ្រែល) ការវាយតម្លៃ និងរបាយការណ៍ចុងក្រោយស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ ២០១២ (ភ្នំពេញ: ខុមហ្វ្រែលឆ្នាំ ២០១២) ទំព័រ៥១

[62] សិទ្ធិ "ការបោះឆ្នោតឆ្នាំ ២០១២ ឃុំ / សង្កាត់" ឆ្នាំ ២០១២

[63] ក្រសួងផែនការ បច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ (ភ្នំពេញ៖ ក្រសួងផែនការឆ្នាំ ២០០៩) ទំព័រ ១៦

[64] **Feiring** ការដាក់បញ្ចូលជនជាតិដើមភាគតិច ទំព័រ ៣៨

សេវាសាធារណៈជាមូលដ្ឋាន ដូចជាផ្នែកសុខភាព និងការអប់រំជាដើម ក៏ប៉ុន្តែជាទូទៅបញ្ហាទាំងនេះកំពុងតែល្អប្រសើរជាងមុន[65]។

## ៣.២. ការស្រាវជ្រាវនៅមូលដ្ឋាន

ការស្រាវជ្រាវនៅមូលដ្ឋាន បានបង្ហាញឲ្យឃើញនូវនិន្នាការទូលំទូលាយចំនួនបួនទាក់ទងនឹងការធ្វើសមាហរណកម្មនយោបាយរបស់ប្រជាជនកម្ពុជា ដែលជាជនជាតិដើមភាគតិច។

ទី១-សហគមន៍ភាគច្រើនដែលបានធ្វើការស្ទង់មតិ គឺជាទូទៅពេញចិត្តភាពជាតំណាងផ្នែកនយោបាយ រួមទាំងអ្វីដែលបានផ្តល់ដល់ពួកគាត់ដោយក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួនផងដែរ។ ឃុំចំនួនបួននៅខេត្តមណ្ឌលគិរី ពេញចិត្តទាំងស្រុងចំពោះក្រុមប្រឹក្សារបស់ពួកគាត់ ប៉ុន្តែសហគមន៍ចំនួនពីរនៅក្នុងខេត្តរតនៈគិរី បានសម្តែងការមិនពេញចិត្តទាល់តែសោះ និងសហគមន៍មួយទៀតបានឆ្លើយថា ពួកគាត់យល់ថា ការបំពេញការងាររបស់ក្រុមប្រឹក្សារបស់ខ្លួន គឺអាចទទួលយកបាន។ បញ្ហាដ៏ធំបំផុត ដែលបណ្តាលឱ្យមានការមិនពេញចិត្ត គឺការមិនសូវអើពើពីសំណាក់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការដោះស្រាយបញ្ហាសិទ្ធិដីធ្លី។ ផ្ទុយទៅវិញ សហគមន៍នៅខេត្តមណ្ឌលគិរីបានថ្លែងថា ពួកគាត់បានសង្កេតឃើញថា មិនមែនមានតែក្រុមប្រឹក្សាឃុំ-សង្កាត់របស់ពួកគាត់ទេ សូម្បីតែអាជ្ញាធរខេត្តក៏សកម្មដែរ និងបានរួមចំណែកច្រើនក្នុងការដោះស្រាយវិវាទប្រហាក់ប្រហែលគ្នានេះ[66]។

ទី២-ក្នុងចំណោមក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងប្រាំពីរនេះ យើងសង្កេតឃើញថា សមាជិកក្រុមប្រឹក្សាភាគច្រើនជាជនជាតិដើមភាគតិច។ សហគមន៍ភាគច្រើនបានឲ្យដឹងថា ក្នុងចំណោមសមាជិកក្រុមប្រឹក្សាប្រាំរូប មានបួនរូបជាជនជាតិដើមភាគតិច រីឯសហគមន៍ពីរទៀតបានឲ្យដឹងថា មានសមាជិកក្រុមប្រឹក្សាទាំងអស់ និងបុគ្គលិករដ្ឋបាលសុទ្ធតែជាជនជាតិដើមភាគតិច។ នេះគឺជាការល្អ ដោយសារតែកត្តានេះតំណាងឱ្យភាពជោគជ័យដ៏សំខាន់សម្រាប់គោលនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា និងការដាក់បញ្ចូលជនជាតិដើមភាគតិចទៅក្នុងប្រព័ន្ធនយោបាយ។ យោងតាមការសម្ភាសដែលយើងបានរៀបចំឡើងបង្ហាញថា សហគមន៍ភាគច្រើនយល់ថា ភាពជាតំណាង និងការបម្រើការងាររបស់រដ្ឋបាលនៅមូលដ្ឋានមានលក្ខណៈល្អប្រសើរ ដោយសារតែសមាជិកក្រុមប្រឹក្សាឃុំភាគច្រើនរបស់ពួកគាត់ជាជនជាតិដើមភាគតិច ដែលយល់ពីតម្រូវការ និងការព្រួយបារម្ភរបស់ពួកគាត់[67]។

---

[65] មេដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី និងមណ្ឌលគិរី -ការស្រាវជ្រាវនៅមូលដ្ឋាន-បទសម្ភាសន៍ជាមួយមេដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

[66] ដូចឯកសារយោងខាងលើ

[67] ដូចឯកសារយោងខាងលើ

ទី៣-ភាពវិជ្ជមានតិចតួចដែលការស្រាវជ្រាវរបស់យើងបានបញ្ជាក់ថា ការដាក់បញ្ចូលស្ត្រីជនជាតិដើមភាគតិចទៅក្នុងក្រុមប្រឹក្សាឃុំ និងការងារនយោបាយនៅមានកម្រិតទាប ហើយកត្តានេះនៅតែជាបញ្ហា[68]។

ទី៤-សហគមន៍ភាគច្រើនដែលបានចូលរួមសម្ភាសន៍បានថ្លែងថា ការទទួលបានការផ្តល់សេវានានារបស់រដ្ឋ ដូចជាសេវាសុខាភិបាល សេវាអប់រំ និងការកែលម្អផ្លូវលំតូចៗ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយនេះ។ លើកលែងតែសហគមន៍ចំនួនពីរប៉ុណ្ណោះនៅក្នុងខេត្តរតនៈគិរី ដែលពួកគាត់បង្ហាញថាមានការពេញចិត្តយ៉ាងខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងទាំងនេះរបស់រាជរដ្ឋាភិបាលកម្ពុជា។ កត្តានេះបានធ្វើឱ្យពួកគាត់យល់ថា ខ្លួនត្រូវបានដាក់បញ្ចូលយ៉ាងទូលំទូលាយនៅក្នុងការអភិវឌ្ឍរបស់ប្រទេសជាតិ[69]។

## ៤. សិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច

សិទ្ធិរបស់ជនជាតិដើមភាគតិចកម្ពុជាទាំងកម្មសិទ្ធិសមូហភាព និងកម្មសិទ្ធិបុគ្គលលើដីប្រពៃណីរបស់ពួកគេត្រូវបានបង្កើតឡើងយ៉ាងល្អដោយច្បាប់ និងអនុក្រឹត្យ។ ច្បាប់ភូមិបាលឆ្នាំ២០០១ បានទទួលស្គាល់ដី សមូហភាពរបស់ជនជាតិដើមភាគតិច។ ដីធ្លីដែលត្រូវបានចាត់ទុកថាជាដីសមូហភាពរបស់ជនជាតិដើមភាគតិចគឺសំដៅទៅលើផ្ទៃដីដែលពួកគេបានដាំដុះពិតប្រាកដ និងជាតម្រូវការសម្រាប់ការធ្វើកសិកម្ម និងការចិញ្ចឹមសត្វសម្រាប់ប្រជាជនជនជាតិដើមភាគតិច[70]។ សិទ្ធិសមូហភាពទាំងនេះ ត្រូវបានចេញឱ្យសម្រាប់ការជួលរយៈពេល១៥ឆ្នាំប៉ុណ្ណោះ ហើយក្នុងអំឡុងពេលនេះផ្ទៃដីទាំងនេះត្រូវតែរក្សាស្ថានដើមដដែលមិនឲ្យមានការប្រែប្រួលឡើយ[71]។ ទំហំផ្ទៃដីសម្រាប់កម្មសិទ្ធិសមូហភាពត្រូវបានកំណត់តាមការអះអាងពីសហគមន៍ជនជាតិដើមភាគតិចនូវអ្វីដែលបង្កើតជាដីប្រពៃណីរបស់ពួកគាត់ ដោយមានការព្រមព្រៀងជាមួយដីអ្នកជិតខាងរបស់ខ្លួន និងមានការឯកភាពដោយក្រសួងមហាផ្ទៃ[72]។ ចំពោះដីរដ្ឋផ្សេងទៀតដែលជាកន្លែងដែលសហគមន៍បានប្រើដើម្បីប្រមូលផលកសិផលពីព្រៃឈើ ឬសម្រាប់ការទទួលបានទឹកប្រើប្រាស់ សហគមន៍អាចរក្សាសិទ្ធិទទួលបានការ ប្រើប្រាស់បន្តទៀត ដោយគ្រាន់តែធ្វើកិច្ចព្រមព្រៀងជាមួយអាជ្ញាធរពាក់ព័ន្ធដែលមានដែនសមត្ថកិច្ចលើផ្ទៃដីទាំងនោះ[73]។ ព័ត៌មានលម្អិតពាក់ព័ន្ធ

---

[68] ដូចឯកសារយោងខាងលើ

[69] ដូចឯកសារយោងខាងលើ

[70] ព្រះរាជាណាចក្រកម្ពុជា-ច្បាប់ភូមិបាល នស / រកម / ០៨០១/១៤ ២០០១ មាត្រា ២៥ ។

[71] ព្រះរាជាណាចក្រកម្ពុជា-អនុក្រឹត្យលេខ ១១៨ អនក្រ/បក ការគ្រប់គ្រងដីរដ្ឋ ឆ្នាំ ២០០៥ មាត្រា ១៥ និង ១៨ ។

[72] ដូចឯកសារយោងខាងលើ

[73] ព្រះរាជាណាចក្រកម្ពុជា-អនុក្រឹត្យលេខ ៨៣ អនក្រ/បក នីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើម ឆ្នាំ ២០០៩ មាត្រា ៧

ដំណើរការវាស់វែង និងការផ្តល់ដីសម្ហហភាពទាំងនេះ មានចែងនៅក្នុងអនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩[74]។

កម្មសិទ្ធិដីសម្ហហភាពផ្តល់ជាសំខាន់ដល់ជនជាតិដើមភាគតិចនូវសិទ្ធិ និងការការពារដូចគ្នា ក្នុងការប្រើប្រាស់ដីធ្លីដូចដីកម្មសិទ្ធិបុគ្គលឯកជនដែរ។ ភាពខុសប្លែកគ្នាដ៏សំខាន់គឺត្រង់ថា កម្មសិទ្ធិដីសម្ហហភាពនៅតែជាដីសាធារណៈរបស់រដ្ឋ ហើយអ្នកកាន់កាប់ដីនេះមិនអាចផ្ទេរឱ្យទៅបុគ្គល ឬក្រុមណាមួយផ្សេងទៀតបានឡើយ [75] ហើយកម្មសិទ្ធិសម្ហហភាពត្រូវបានកាន់កាប់ដោយសហគមន៍ទាំងមូល មិនមែនបុគ្គលណាម្នាក់របស់សហគមន៍ឡើយ[76]។ នៅក្នុងបណ្តាប្រទេសផ្សេងៗ ក៏គ្មានបុគ្គលណាម្នាក់នៅក្នុងសហគមន៍មានកម្មសិទ្ធិឯកជន ឬមានសិទ្ធិលើដីសម្ហហភាពដែរ[77]។ មានការបង្ហើបឲ្យដឹងថា ដីកម្មសិទ្ធិសម្ហហភាពអាចត្រូវបានកែសម្រួលសំដៅជួយសម្រួលដល់ការងាររបស់រដ្ឋដើម្បីផលប្រយោជន៍របស់ជាតិ ឬវិធានការបន្ទាន់របស់ជាតិ [78]។ ការគ្រប់គ្រងដីសម្ហហភាពនេះត្រូវបានផ្តល់ជូនឱ្យដោយអាជ្ញាធរប្រពៃណី នៃសហគមន៍ជនជាតិដើមភាគតិច[79]។ ទោះជាយ៉ាងណា ជនជាតិដើមភាគតិចក៏មានសិទ្ធិទទួលបានកម្មសិទ្ធិឯកជនដែរ។ ក្នុងករណីនេះ បុគ្គលជនជាតិដើមភាគតិចដែលពាក់ព័ន្ធអាចចាកចេញពីសហគមន៍ និងចរចាស្នើសុំផ្នែកណាមួយនៃដីសម្ហហភាពដើម្បីបែងចែកបុគ្គលទាំងនោះបាន[80]។

ដើម្បីមានសិទ្ធិទទួលបានកម្មសិទ្ធិដីសម្ហហភាព សហគមន៍នោះត្រូវតែមានការចុះបញ្ជីនៅក្រសួងមហាផ្ទៃ ទាំងជនជាតិដើមភាគតិច និងនីតិបុគ្គលនោះ[81]។ នៅពេលដែលមានការទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ អាជ្ញាធរ ឬប្រធានគណៈកម្មការសហគមន៍[82] ត្រូវបើកដំណើរការនីតិវិធីចុះបញ្ជីដីធ្លីរបស់ពួកគាត់នៅការិយាល័យស្រុក/ក្រុង នៃមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីឲ្យដីដែលបាន
ចុះបញ្ជីនោះស្ថិតក្រោមកម្មសិទ្ធិដីធ្លីសម្ហហភាព និងមាននៅលើផែនទីសុរិយោដីតែមួយ[83]។ ផ្ទៃដីដែលមានសិទ្ធិទទួលបានការចុះបញ្ជីកម្មសិទ្ធិសម្ហហភាពរួមមានដីឯកជនរបស់រដ្ឋ (ក)

---

[74] ដូចឯកសារយោងខាងលើ

[75] ព្រះរាជាណាចក្រកម្ពុជា- ច្បាប់ភូមិបាល មាត្រា ៧

[76] ព្រះរាជាណាចក្រកម្ពុជា-អនុក្រឹត្យលេខ ៨៣ មាត្រា ៤

[77] ដូចឯកសារយោងខាងលើ មាត្រា ១៤

[78] ព្រះរាជាណាចក្រកម្ពុជា- ច្បាប់ភូមិបាល

[79] ដូចឯកសារយោងខាងលើ

[80] ដូចឯកសារយោងខាងលើ មាត្រា ២៧

[81] ព្រះរាជាណាចក្រកម្ពុជា-អនុក្រឹត្យលេខ ៨៣ មាត្រា ៣ និង ៥

[82] សំដៅទៅលើមេដឹកនាំរបស់សហគមន៍ដែលជ្រើសរើសដោយសមាជិកទាំងអស់នោះ។ សូមមើលមាត្រា ៤ អនុក្រឹត្យលេខ ៨៣ អនក្រ.បក

[83] ព្រះរាជាណាចក្រកម្ពុជា-អនុក្រឹត្យលេខ ១១៨ មាត្រា ៥ និង ៨

ឧទាហរណ៍ ដីលំនៅដ្ឋាន ឬដីដែលសមាជិកសហគមន៍ណាម្នាក់បានសាងសង់ផ្ទះរបស់ពួកគាត់ និងដីដែលជាសមាជិកសហគមន៍ណាម្នាក់បានប្រកបរបរកសិកម្មរបស់ពួកគាត់ (ខ)( ដីសាធារណៈរបស់រដ្ឋ ឧទាហរណ៍ ដីបម្រុងទុកចាំបាច់សម្រាប់ការផ្លាស់ប្តូរការដាំដុះ[84] ដែលត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាលពាក់ព័ន្ធ និងមានការឯកភាពពីដីរបស់អ្នកជិតខាងរបស់ពួកគាត់ ដីជំនឿប្រពៃណី[85] ដែលមានទំហំមិនលើសពីប្រាំពីរហិកតា និងដីព្រៃបញ្ចុះសពដែលមិនលើសពីប្រាំពីរហិកតា[86]។

សម្បទានដីសេដ្ឋកិច្ច មានតែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទេ ដែលមានសិទ្ធិអនុញ្ញាតផ្តល់ឲ្យ។ សិទ្ធិអំណាចនេះត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០០៥ [87]។ សម្បទានបែបនេះ គឺសម្រាប់សកម្មភាពសេដ្ឋកិច្ចឯកជនដែលអាចត្រូវបានផ្តល់ឲ្យ ដរាបណាដីនោះត្រូវបានចុះឈ្មោះរួចជាស្រេចសម្រាប់ការប្រើប្រាស់ឯកជន ដែលបានស្នើប្រើប្រាស់សម្រាប់ផែនការណាដែលឆ្លើយតបទៅនឹងផែនការប្រើប្រាស់ដីមានស្រាប់របស់ខេត្តស្របទៅតាមការវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានរៀបចំ និងមានដំណោះស្រាយសម្រាប់ដោះស្រាយបញ្ហានានាដែលបានកំណត់[88]។ តាមទ្រឹស្តី បញ្ហានេះគួរតែមានការការពារផលប្រយោជន៍របស់ជនជាតិដើមភាគតិចដែលមានដីកាន់កាប់ គឺទាំងដីសាធារណៈ ឬដីឯកជន ដើម្បីចៀសផុតពីការចាត់ចូលជាសម្បទានដីសេដ្ឋកិច្ច[89]។

## ៤.១. ការយល់ដឹងអំពីសិទ្ធិទាំងនេះ-បញ្ហា និងដំណោះស្រាយ

សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា មានការទទួលស្គាល់ពីការទទួលបានដីធ្លីជាបន្តបន្ទាប់ដែលភាគច្រើនជាតំបន់ដីព្រៃធំដែលគ្មានការអភិវឌ្ឍ ដែលនេះជាសិទ្ធិដ៏សំខាន់បំផុតរបស់ពួកគាត់។ ការណ៍នេះ គឺដោយសារតែការបង្កើតមូលដ្ឋាននៃការរស់នៅក្នុងសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់ពួកគាត់[90]។ ទោះជាយ៉ាងណា គេឃើញមាន

---

[84]សំដៅទៅលើដីដែលបានប្រើពីមុនដោយសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ដែលជាវាលស្រែ ឬកសិដ្ឋានសម្រាប់ការដាំដុះប្តូរប្រពៃណី។ សូមមើលមាត្រា ៩ អនុក្រឹត្យលេខ ៨៣ អនក្រ.បក

[85] សំដៅទៅលើកន្លែងដែលសហគមន៍បានរក្សាសម្រាប់គោរពបូជា ឬការប្រោរព្ធពិធីសាសនាប្រពៃណី។ សូមមើលមាត្រា ៩ នៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក

[86] ព្រះរាជាណាចក្រកម្ពុជា-អនុក្រឹត្យលេខ ៨៣ មាត្រា ៦

[87] ព្រះរាជាណាចក្រកម្ពុជា-អនុក្រឹត្យលេខ ១៤៦ អនក្រ/បក សម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥ មាត្រា ៤២

[88] ដូចឯកសារយោងខាងលើ មាត្រា ៩

[89] សុរិយា ប្រាសាទ ស៊ូបេឌី: របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា: ការវិភាគអំពីសិទ្ធិមនុស្សនៃសម្បទានដីសេដ្ឋកិច្ច និងដីសម្បទានផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា (ទីក្រុងញូវយ៉ក៖ មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ២០១២), **http://daccess-dds- ny.un.org/doc/UNDOC/GEN/G12/175/03/PDF/G1217503. pdf?OpenElement.**

[90] **Feiring** ការដាក់បញ្ចូលជនជាតិដើមភាគតិច ទំព័រ ៣៨

វិវាទសំខាន់មួយរវាងទស្សនវិស័យបែបនេះ និងគោលការណ៍ស្នូលនៃគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការអភិវឌ្ឍ ដែលមានចក្ខុវិស័យក្នុងការបង្កើតកសិឧស្សាហកម្មដែលមានផលិតភាពខ្ពស់ជាង ដូចជាចម្ការកៅស៊ូ ចម្ការអំពៅ និងចម្ការស្វាយចន្ទី ក្នុងគោលបំណងបង្កើតប្រាក់ចំណូលទាំងសម្រាប់ការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ និងការពង្រឹងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាទាំងមូល[91]។

ការសិក្សាមួយដែលធ្វើឡើងនៅឆ្នាំ២០០៨ បានរកឃើញថា ៥៣ភាគរយនៃបញ្ហាជម្លោះដីធ្លីរបស់ជនជាតិដើមភាគតិចគឺជាប់ពាក់ព័ន្ធនឹងដីកសិកម្ម ហើយបញ្ហាដែលនៅសេសសល់គឺមានភាពប្រទាញប្រទង់គ្នារវាងដីលំនៅដ្ឋាន ដីភូមិ និងដីព្រៃសហគមន៍[92]។ ការសិក្សានេះ និងការស្រាវជ្រាវជាបន្តបន្ទាប់ បានរកឃើញនូវទិដ្ឋភាពសំខាន់ៗចំនួនពីរដែលបណ្តាលឱ្យកើតមានជម្លោះទាំងនេះ៖ ជនជាតិដើមភាគតិចយល់ព្រមលក់ដីរបស់ពួកគេ ដោយពុំបានយល់ដឹង ឬទទួលស្គាល់នូវផលវិបាកទាំងឡាយនៅពេលដែលពួកគេលែងមានសិទ្ធិប្រើប្រាស់ដីដែលពួកគេលក់នោះសម្រាប់បន្តធ្វើកសិកម្មបានទៀតឡើយ ហើយសហគមន៍ជនជាតិដើមភាគតិចក៏នឹងបាត់បង់សិទ្ធិគ្រប់គ្រងលើដីធ្លីរបស់ពួកគេដែរ[93]។ បញ្ហាទាក់ទងនឹងការបាត់បង់សិទ្ធិគ្រប់គ្រងលើដីធ្លី អាចកើតមានឡើងទៅតាមរូបភាពមួយចំនួនដូចជា មនុស្សដែលមានអំណាចដាក់សម្ពាធទៅលើសហគមន៍ជនជាតិដើមភាគតិច ការទទួលបានការអនុញ្ញាតពីអ្នកភូមិណាម្នាក់ក្នុងការកាន់កាប់ដីធ្លីជាច្រើនរបស់ភូមិមួយដែលគាត់មិនមានសិទ្ធិក្នុងការលក់ដូរ ការអនុវត្តច្បាប់មិនបានសមស្រប និងដោយមានភាពមិនច្បាស់លាស់ ដែលបណ្តាលឱ្យមានភាពមិនច្បាស់លាស់ថាតើនរណាមានសិទ្ធិរក្សាទុកប័ណ្ណកាន់កាប់ដីធ្លី ឬនរណាមានសិទ្ធិកាន់កាប់ដីធ្លីដោយគ្មានការអនុញ្ញាតតែម្តង[94]។

បញ្ហានេះផ្នែកមួយអាចមើលត្រឡប់ទៅក្រោយវិញនូវអ្វីដែលអង្គការពលកម្មអន្តរជាតិ **(ILO)** បានរកឃើញនៅឆ្នាំ ២០០៨ ថាបណ្តាលមកពីកង្វះខាតនូវការផ្ទេរព័ត៌មានទាំងស្រុងរវាងសហគមន៍ជនជាតិដើមភាគតិច និងច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍនានាដែលមានផលប៉ះពាល់ដល់ពួកគេ[95]។ របាយការណ៍ដដែលនេះក៏កំណត់បាននូវបញ្ហានានាពាក់ព័ន្ធនឹងដីធ្លី ដែលមានសារៈសំខាន់បំផុតចំពោះប្រជាជនដែលជាជនជាតិដើមភាគតិចរស់នៅក្នុងប្រទេសកម្ពុជា ហើយបានបន្ថែមថា ការចុះបញ្ជីដីធ្លីជូនជនជាតិដើមភាគ

---

[91] សម្តេចតេជោ ហ៊ុន សែន យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី **III (**ភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១៣**)** **http://www.cambodiainvestment.gov.kh/content/uploads/2013/11/2013-**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី**III-En8.pdf**

[92] ទំព័រ ៧

[93] មូល ផាត និងសុឌ្ឍនា សេង កំណត់ត្រាបច្ចេកទេសទូទាំងប្រទេស ស្តីពីបញ្ហាជនជាតិដើមភាគតិច៖ ព្រះរាជាណាចក្រកម្ពុជា **(**ទីក្រុងរ៉ូម៖ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម ឆ្នាំ ២០១២**)**

[94] ដូចឯកសារយោងខាងលើ

[95] **Feiring** ការដាក់បញ្ចូលជនជាតិដើមភាគតិច ទំព័រ ១៨

តិច និងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចទាំងនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការការពារសិទ្ធិដីធ្លីរបស់ពួកគាត់[96]។

ខណៈពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យមានការរីកចម្រើនជាច្រើនក្នុងការដោះស្រាយបញ្ហាទាំងនេះ ដោយផ្តោតជាចម្បងលើការអនុញ្ញាតឲ្យមានប័ណ្ណកាន់កាប់ដីធ្លីសម្ងហភាពរបស់សហគមន៍ជនជាតិដើមភាគតិច[97]ដែលបានចុះបញ្ជី ដែលដំណើរការនេះត្រូវការធនធានច្រើនជាងមុនដើម្បីធានាឲ្យមានប្រសិទ្ធភាពសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច[98]។ ជាទូទៅ លទ្ធផលនៃកិច្ចប្រឹងប្រែងនេះ គឺដំណើរការយឺតយ៉ាវក្នុងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាមួយក្រសួងមហាផ្ទៃ បន្ទាប់មកនៅមានដំណើរការដ៏វែងឆ្ងាយជាលើកទីពីរទៀតគឺការចុះបញ្ជីដីសហគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។ កត្តានេះបានបណ្តាលឲ្យមានករណីមួយចំនួនដែលដីសហគមន៍ជនជាតិដើមភាគតិច ត្រូវបានកាន់កាប់សម្រាប់ប្រើប្រាស់ក្នុងគោលបំណងពាណិជ្ជកម្មដូចជាការផ្តល់ដីសម្បទានព្រៃឈើ ឬដីសម្បទានសេដ្ឋកិច្ច ខណៈពេលដែលការដាក់ពាក្យស្នើសុំប័ណ្ណកាន់កាប់ដីសម្ងហភាពរបស់សហគមន៍ត្រូវបានកំពុងរង់ចាំការអនុម័តយល់ព្រម[99]។

ការអភិវឌ្ឍ ព្រៃឈើ និងការបង្កើតឧស្សាហកម្មនានាជាបន្តបន្ទាប់ ដូចជាចំការកៅស៊ូជាដើមបានបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនដែលជាជនជាតិដើមភាគតិចរបស់ប្រទេសកម្ពុជា[100]។ ការប្រែប្រួលទាំងនេះបានសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ដូចនៅក្នុងផែនទីដែលបានបង្ហាញជូនខាងក្រោមនេះ។ ផែនទី ៤ បង្ហាញអំពីស្រុកមួយចំនួនក្នុងខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី ដែលជាកន្លែងដែល **PIC** បានចុះធ្វើការស្រាវជ្រាវដល់មូលដ្ឋានសម្រាប់គម្រោងនេះ រីឯផែនទី ៥ បង្ហាញពីគម្របព្រៃឈើក្នុងតំបន់នោះកាលពីឆ្នាំ ១៩៧៣ ដោយក្នុងផែនទីនោះ ពណ៌បៃតងចាស់តំណាងឱ្យតំបន់ព្រៃឈើក្រាស់ ព័ណ៌បៃតងខ្ចីតំណាងឱ្យតំបន់ព្រៃឈើមិនសូវក្រាស់ រីឯព័ណ៌ទឹកក្រូចតំណាងឱ្យតំបន់ដែលពុំមានព្រៃឈើ។

---

[96] ដូចឯកសារយោងខាងលើ ទំព័រ ៣៩

[97] ធនាគារអភិវឌ្ឍន៍អាស៊ី **(ADB)** ការការពារសុវត្ថិភាពជនជាតិដើមភាគតិច: ការធ្វើផែនការ និងការអនុវត្តបទពិសោធន៍%ល្អ១-សេចក្តីព្រាងសៀវភៅប្រភពឯកសារការងារ **(**ក្រុងម៉ានីល៖ ធនាគារអភិវឌ្ឍន៍អាស៊ី ២០១៣**)**

[98] សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា(ទីក្រុងញូវយ៉ក៖ វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ២០១០)ទំព័រ ៧-៨

[99] ដូចឯកសារយោងខាងលើ

[100] បណ្តាញតំណាងជនជាតិដើមភាគតិច, វិបត្តិចំពោះមុខរបស់ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា៖ ការដាក់ស្នើដោយជនជាតិដើមភាគតិចនៃប្រទេសកម្ពុជាទៅកាន់កិច្ចប្រជុំតំបន់អាស៊ីរបស់វេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីពីបញ្ហារបស់ជនជាតិដើមភាគតិច នៅប្រទេសម៉ាឡេស៊ីនៅថ្ងៃទី ៤-៦ ខែមិនាឆ្នាំ២០០៩ **(**ម៉ាឡេស៊ី ២០០៩)ទំព័រ ៣-៤






ផែនទី ៤ - ស្រុកដែលបានទៅចុះផ្ទាល់នៅខេត្តរតនៈគិរី [101] ផែនទី ៥ - គម្របព្រៃឈើក្នុងឆ្នាំ ១៩៧៣[102]
និងខេត្តមណ្ឌលគិរី

ស្រដៀងគ្នានេះដែរ ផែនទី ៦ និងផែនទី ៧ ខាងក្រោមនេះ បង្ហាញពីបរិមាណព្រៃឈើក្នុងឆ្នាំ២០០៤ និងក្នុងឆ្នាំ២០១៣។ ផែនទីទាំងនេះ ដែលយោងតាមរូបភាពផ្កាយរណបរបស់អង្គការណាសា គឺបង្ហាញឲ្យឃើញនូវការកាត់បន្ថយដ៏ច្រើន និងជាបន្តបន្ទាប់នូវតំបន់ព្រៃឈើនៅក្នុងស្រុកមួយចំនួនដែលមានប្រជាជនដែលជាជនជាតិដើមភាគតិចរស់នៅច្រើន។

---

[101] ប្រទេសកម្ពុជាការអភិវឌ្ឍដោយបើកចំហ "ផែនទី សេដ្ឋកិច្ចសង្គម នៃប្រទេសកម្ពុជា" ។
[102] ដូចឯកសារយោងខាងលើ





ផែនទី ៦ -គម្របព្រៃឈើក្នុងឆ្នាំ២០០៤[103]  ផែនទី ៧ - គម្របព្រៃឈើក្នុងឆ្នាំ២០១៣[104]

វិវាទរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់ដីសហាគមន៍ ក៏ដូចជាតំបន់បម្រុងទុកធម្មជាតិ ត្រូវបានសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់នៅក្នុងផែនទីខាងក្រោមនេះ។ ផែនទី ៨ បង្ហាញអំពីព្រៃការពាររបស់សហាគមន៍ ឧទ្យានជាតិ ជម្រកសត្វព្រៃនៅក្នុងតំបន់ដែលបានធ្វើការស្ទង់មតិ ខណៈដែលផែនទី ៩ បង្ហាញអំពីទីតាំងដីសម្បទានសេដ្ឋកិច្ច រីឯផែនទី ១០ បង្ហាញអំពីទីតាំងនៃដីសម្បទានព្រៃឈើ។ តំបន់ត្រួតស៊ីគ្នាដ៏ច្រើនដែលកើតចេញពីការកំណត់ព្រំប្រទល់តំបន់មិនត្រូវគ្នាគឺអាចមើលឃើញយ៉ាងច្បាស់នៅក្នុងផែនទីទាំងនេះ ដែលបង្ហាញពីវិវាទនៅក្នុងតំបន់ រវាងការផ្តល់នូវទំហំដីអភិរក្សចាំបាច់ដើម្បីការពារសិទ្ធិដីធ្លី និងប្រពៃណីរបស់ជនជាតិដើមភាគតិច និងការកើនឡើងនូវសកម្មភាពសេដ្ឋកិច្ចដែលត្រូវបានអនុវត្តដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។

---

103 ប្រទេសកម្ពុជាការអភិវឌ្ឍដោយបើកចំហ “ផែនទី សេដ្ឋកិច្ចសង្គម នៃប្រទេសកម្ពុជា” ។
104 ដូចឯកសារយោងខាងលើ





ផែនទី ៨ -ព្រៃការពារ [105] ផែនទី ៩-ដីសម្បទានសេដ្ឋកិច្ច[106] ផែនទី ៩-ដីសម្បទានព្រៃឈើ[107]

## ៤.២. ការចុះស្រាវជ្រាវដល់មូលដ្ឋាន

ការស្រាវជ្រាវដែលបានធ្វើឡើងនៅក្នុងខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី បានបញ្ជាក់យ៉ាងច្បាស់លើការស្រាវជ្រាវដែលមានស្រាប់ថាត្រឹមត្រូវៈ ប្រជាជនជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាមានការព្រួយបារម្ភ និងរងផលប៉ះពាល់ដោយសារការអភិវឌ្ឍសេដ្ឋកិច្ច ដូចជាសកម្មភាពកាប់ព្រៃឈើក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចដែលកាត់បន្ថយការទទួលផលរបស់ពួកគេពីព្រៃឈើ[108]។

ទោះជាយ៉ាងណា ពាក់ព័ន្ធនឹងបញ្ហាដីធ្លី គឺមានភាពខុសគ្នាយ៉ាងខ្លាំងរវាងបទពិសោធន៍ និងការយល់ឃើញរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានធ្វើបទសម្ភាសន៍នៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរីដោយដំបូងឡើយសង្កេតឃើញថាមានភាពអវិជ្ជមានខ្លាំង និងក្រោយមកទៀតឃើញថាមានការប្រែក្លាយមកជាវិជ្ជមានខ្លាំងវិញ។

ជាពិសេស បណ្តាភូមិនៅក្នុងខេត្តរតនៈគិរីទាំងអស់បានលើកឡើងថា បញ្ហាដីធ្លីគឺជាក្តីបារម្ភដ៏ធំបំផុតរបស់ពួកគេ។ បញ្ហាដ៏ធំបំផុតដែលទាក់ទងនឹងអ្វីដែលបានកំណត់នៅក្នុងផ្នែកខាងលើៈ ដែលជានិច្ចកាលព័ត៌មានអំពីរបៀបដើម្បីដាក់ពាក្យស្នើសុំការទទួលស្គាល់ថាជាសហ

[105] ដូចឯកសារយោងខាងលើ

[106] ដូចឯកសារយោងខាងលើ

[107] ដូចឯកសារយោងខាងលើ

[108] មេដឹកនាំសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនៈគិរី និងមណ្ឌលគិរី- ការស្រាវជ្រាវមូលដ្ឋាន-កិច្ចសម្ភាសមេដឹកនាំសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តមណ្ឌលគិរី និងរតនៈគិរី

គមន៍ជនជាតិដើមភាគតិច និងអំពីរបៀបចុះបញ្ជីដីសម្ហូហភាពជាមួយក្រសួងមហាផ្ទៃ ត្រូវបានយល់ដឹងតិចតួចនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ហើយវាជាដំណើរការមួយដែលមានភាពយឺតយ៉ាវ[109]។ ភូមិចំនួនពីរក្នុងចំណោមភូមិបីនៅក្នុងខេត្តរតនគិរីបានឆ្លើយថាពួកគាត់បានចុះឈ្មោះជាសហគមន៍ជនជាតិដើមភាគតិចរួចហើយ។ ភូមិមួយក្នុងចំណោមភូមិទាំងពីរនេះបានចាប់ផ្ដើមដាក់ពាក្យស្នើសុំប័ណ្ណកាន់កាប់ដីសម្ហូហភាព ប៉ុន្ដែក្នុងអំឡុងពេលដំណើរការដាក់ពាក្យស្នើសុំនេះ ព្រៃឈើមួយចំនួនរបស់ពួកគាត់កំពុងត្រូវបានឈូសឆាយ ខណៈពេលដែលភូមិដទៃទៀតមិនបានដឹងអំពីរបៀបដើម្បីដាក់ពាក្យស្នើសុំប័ណ្ណកាន់កាប់ដីសម្ហូហភាពនោះទេ។ ភូមិទីបីមិនបានដឹងអំពីរបៀបក្នុងការចុះបញ្ជីជាសហគមន៍ជនជាតិដើមភាគតិច ឬមិនបានដឹងអំពីការដាក់ពាក្យស្នើសុំប័ណ្ណកាន់កាប់ដីសម្ហូហភាពនោះដែរ[110]។ បញ្ហាស្រដៀងគ្នានេះ គឺការទទួលយកប័ណ្ណកាន់កាប់ដីធ្លីឯកជនរៀងៗខ្លួនដោយសមាជិកនៅក្នុងសហគមន៍។ ខណៈពេលដែលមានការធានាអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានដីធ្លី មេភូមិបានឆ្លើយថាកត្តានេះធ្វើឲ្យចុះខ្សោយនូវអត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច ដែលពួកគេយល់ថាដីសហគមន៍គឺជារឿងសំខាន់[111] ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងខេត្តមណ្ឌលគិរី ស្ថានភាពដែលបានបង្ហាញឲ្យដឹងដោយសហគមន៍ជនជាតិដើមភាគតិចដែលបានធ្វើបទសម្ភាសន៍ គឺមានភាពខុសគ្នាខ្លាំងណាស់។ ខណៈពេលដែលឃុំទាំងអស់ បានឆ្លើយថាដីធ្លីរបស់ពួកគាត់មានការថយចុះក្នុងអំឡុងពេលដប់ឆ្នាំចុងក្រោយនេះ ហើយពួកគាត់បានឱ្យដឹងថាព្រៃសហគមន៍របស់ពួកគាត់សមស្របនឹងតម្រូវការរបស់ខ្លួន និងបានបញ្ជាក់ថាពួកគេមានការសប្បាយរីករាយយ៉ាងខ្លាំងជាមួយនឹងការរៀបចំបែបនេះ។ ឃុំចំនួនបីក្នុងចំណោមឃុំបួនក៏បានទទួលយកកម្មសិទ្ធិដីធ្លីឯកជនបន្ថែមពីលើកម្មសិទ្ធិសម្ហូហភាពដីព្រៃសហគមន៍របស់ពួកគេ។ ឃុំមួយបានគេបដិសេធមិនឲ្យមានកម្មសិទ្ធិឯកជន ដោយសារពួកគេភ័យខ្លាចថាវានឹងបណ្ដាលឲ្យចុះខ្សោយការអនុវត្តវប្បធម៌ជនជាតិដើមភាគតិចរបស់ខ្លួន។ ឃុំទាំងនេះបានឆ្លើយថាបញ្ហាដែលពាក់ព័ន្ធនឹងដីធ្លីធំជាងគេបំផុត គឺថាសត្វពាហនៈរបស់អ្នកភូមិពេលខ្លះត្រូវបានគេសម្លាប់នៅដែលពួកវាដើររកចំណីនៅលើដីកសិដ្ឋាន ឬដីចំការឯកជនដែលគេទិញដោយស្របច្បាប់ [112] ។ ជាមួយគ្នានេះក៏មានការបញ្ជាក់យ៉ាងច្បាស់អំពីលទ្ធផលនៃការរកឃើញរបស់មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម ដែលបានលើកឡើងនៅក្នុងផ្នែកខាងលើ ដែលបានសង្កេតឃើញថាបញ្ហាទូទៅមួយគឺថាសមាជិកនៃសហគមន៍ជនជាតិដើមភាគ

---

[109] **Feiring** ការដាក់បញ្ចូលជនជាតិដើមភាគតិច ទំព័រ ៧-៨

[110] មេដឹកនាំសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនៈគិរី និងមណ្ឌលគិរី- ការស្រាវជ្រាវមូលដ្ឋាន-កិច្ចសម្ភាសមេដឹកនាំសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តមណ្ឌលគិរី និងរតនៈគិរី

[111] ដូចឯកសារយោងខាងលើ

[112] ដូចឯកសារយោងខាងលើ

តិចមិនបានយល់ច្បាស់ថា ការលក់ដីរបស់ខ្លួនគឺមានន័យថាពួកគេពុំមានសិទ្ធិប្រើប្រាស់ដីនោះបន្តទៀតសម្រាប់ការធ្វើកសិកម្ម ឬការចិញ្ចឹមសត្វនោះទេ[113]។

ដោយសារតែមានតម្រូវការដីខុសៗគ្នា រវាងគោលបំណងសំខាន់របស់ប្រជាជនជនជាតិដើមភាគតិចគឺការបង្កើនការអភិរក្សព្រៃឈើ[114] និងតម្រូវការរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីជំរុញការដាំដុះក្នុងគោលបំណង ដើម្បីបង្កើនផលិតភាពជនបទដើម្បីកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច[115] នឹងបង្កឲ្យមានការប៉ះទង្គិចគ្នាក្នុងកម្រិតណាមួយជាក់ជាពុំខាន។ ទោះជាយ៉ាងណាការស្រាវជ្រាវនៅមូលដ្ឋានដែលបានធ្វើឡើងបានបង្ហាញថាអាជ្ញាធរពាក់ព័ន្ធរបស់ខេត្ត និងស្រុកនៅពេជ្រចិន្តាក្នុងខេត្តមណ្ឌលគិរី បានអនុវត្តគោលនយោបាយដីធ្លីរបស់រដ្ឋាភិបាលថ្នាក់កណ្តាលបានយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធិភាព ដែលអាចឆ្លើយតបបានទាំងការបំពេញតម្រូវការរបស់សហគមន៍ជនជាតិដើមភាគតិចនៅមូលដ្ឋាន និងការឆ្លើយតបទៅនឹងតម្រូវការនៃយុទ្ធសាស្ត្រចតុកោណទីបីឱ្យកាន់តែប្រសើរឡើងនូវការលើកកម្ពស់ផលិតភាពនៅតាមជនបទ តាមរយៈការដាំដុះខ្នាតធំ[116]។ ការអនុញ្ញាតឱ្យមានការកាប់បំផ្លាញព្រៃឈើមួយចំនួនក្នុងស្រុកដែលបានបង្ហាញនៅក្នុងផែនទី៧ខាងលើ គឺជាការប្រឆាំងនឹងវិចារណញ្ញាណរបស់ខ្លួន ក៏ប៉ុន្តែវាក៏បានបង្ហាញដែរថាប្រសិទ្ធិភាពនៃការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលដែលមានស្រាប់នៅថ្នាក់ស្រុកអាចសម្រេចបាននូវតុល្យភាពផលប្រយោជន៍រវាងសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

## សេចក្តីសន្និដ្ឋាន

បើទោះបីប្រជាជនកម្ពុជាជនជាតិដើមភាគតិច ត្រូវបានគេផ្តល់សិទ្ធិស្មើគ្នានៅក្រោមច្បាប់របស់ប្រទេសជាតិក៏ដោយ ក៏ពួកគេនៅតែត្រូវបានចាត់ទុកថាមានភាពក្រីក្រជាងកម្រិតមធ្យមថ្នាក់ជាតិពាក់ព័ន្ធនឹងស្ថានភាពអប់រំ និងការថែទាំសុខភាព។ ទោះបីជាយ៉ាងណា វិស័យទាំងពីរនេះកំពុងមានការរីកចម្រើន ហើយឥឡូវនេះប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ថា ជាគំរូមួយនៃការអនុវត្តដ៏ល្អបំផុតក្នុងការផ្តល់ការអប់រំដល់ប្រជាជនជនជាតិដើមភាគតិច។ ប្រជាជនជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាត្រូវបានមើលឃើញថាបានធ្វើសមាហរណកម្មក្នុងប្រព័ន្ធនយោបាយរបស់ប្រទេសនេះ ដោយមានក្រុមប្រឹក្សាឃុំ-សង្កាត់សម្រាប់ធ្វើជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការទំនាក់ទំនងនូវតម្រូវការរបស់សហគមន៍ជនជាតិដើមភាគតិចទៅកាន់ថ្នាក់លើរបស់រដ្ឋាភិបាល និងដើម្បីអនុវត្តគោលនយោបាយរ

[113] ផាត និងសេង-បញ្ហាផ្សេងៗរបស់ជនជាតិដើមភាគតិច

[114] Feiring ការដាក់បញ្ចូលជនជាតិដើមភាគតិច ទំព័រ ៣៩

[115] សម្តេចតេជោហ៊ុនសែន, យុទ្ធសាស្ត្រចតុកោណ៖ ជំហានទី III ទំព័រ ៧-៨

[116] ដូចឯកសារយោងខាងលើ

ដ្ឋាភិបាលនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។ បញ្ហាដែលពាក់ព័ន្ធទៅនឹងសិទ្ធិដីធ្លីនៅតែជាបញ្ហាស្មុគស្មាញបំផុត ប៉ុន្តែទោះជាយ៉ាងណា ស្រុកពេជ្រចិន្តាក្នុងខេត្តមណ្ឌលគិរី បានផ្តល់នូវគំរូដ៏ជោគជ័យមួយនៃការការពារសិទ្ធិដីធ្លីជនជាតិដើមភាគតិច និងការសម្រួលដល់កំណើនសេដ្ឋកិច្ចតាមរយៈការអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់បានយ៉ាងឆាប់រហ័ស និងត្រឹមត្រូវ។

# គន្ថនិទ្ទេស


ធនាគារអភិវឌ្ឍន៍អាស៊ី **(ADB)** ការការពារសុវត្ថិភាពជនជាតិដើមភាគតិចៈ ឯកសារព្រាងនៃសៀវភៅធ្វើផែនការ និងការអនុវត្តបទពិសោធន៍ល្អៗ ។ ក្រុងម៉ានីលៈ ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ ២០១៣

**Carol, Benson.** ការវាយតម្លៃស្តីពីស្ថានភាពនៃការអប់រំពីរភាសានៅក្នុងប្រទេសកម្ពុជា។ រាជធានីភ្នំពេញៈ ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ ២០១១។

**http://www.careevaluations.org/Evaluations/Final%20report%20BE%20evaluation%20Benson%20FINAL%20DRAFT%2022Mar.pdf.**

**Chakma, Prasenjit** ការបញ្ចូលទស្សនវិស័យរបស់ជនជាតិដើមភាគតិចនៅក្នុងដំណើរការអភិវឌ្ឍប្រទេសៈ ការសិក្សាឡើងវិញអំពី **CCAs** និង**UNDAFs** ដែលបានជ្រើសរើស, ញូវយ៉កៈ វេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច ឆ្នាំ២០០៨

**Chap, Chey, The In, and Anne Thomas.** “ការអប់រំពីរភាសានៅប្រទេសកម្ពុជា" ការអប់រំពីរភាសានៅប្រទេសកម្ពុជា។ បាងកក ឆ្នាំ ២០០៣។

**http://www.silinternational.com/asia/ldc/parallel_papers/he_chey_chap.pdf.**

**Feiring, Birgitte.** ការរួមបញ្ចូលជនជាតិដើមភាគតិចទៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រៈ គោលការណ៍អនុវត្តន៍ផ្អែកលើបទពិសោធន៍ពីប្រទេសកម្ពុជា កាមេរូន និងណេប៉ាល់។ ហ្សឺណែវៈ អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០៨, **http://www.ilo.org/wcmsp5/groups/public/---ed_norm/---normes/documents/publication /wcms_097721.pdf.**

សុខភាពគ្មានព្រំដែន-ការបំពេញការងាររបស់ស្ត្រីជនជាតិដើមភាគតិចឆ្ពោះទៅការលើកកម្ពស់សុខភាពមាតា។ ខេត្តរតនគិរីៈ សុខភាពគ្មានព្រំដែនឆ្នាំ២០០៦

**Heineke, Corinna** និង **Sara Edwards** វិសមភាពសុខភាពរបស់ជនជាតិដើមភាគតិច និងក្រុមមដែលមាន ជាតិសាសន៍និងវប្បធម៌ - ការប្រែប្រួលតាមរយៈក្របខណ្ឌអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥ - ពិភពលោកដែលយើងចង់បានៈ ដំណោះស្រាយវិសមភាព។ ទីក្រុងហ្សឺណែវៈ អង្គការអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ឆ្នាំ២០១២

ថ្នាក់ដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរីនិងខេត្តមណ្ឌលគិរី។ ការចុះស្រាវជ្រាវដល់មូលដ្ឋាន ដោយធ្វើបទសម្ភាសន៍ជាមួយថ្នាក់ដឹកនាំសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរីនិងខេត្តមណ្ឌលគិរី, ធ្វើបទសម្ភាសន៍ដោយ **Sebastian Abjorensen** បកប្រែដោយ **San Sokprapey,** ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤។

អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច។ “ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា” ឆ្នាំ ២០១០ ។

**http://www.icso.org.kh/indigenous-people/indigenous-people-in-cambodia/.**

បណ្តាញតំណាងជនជាតិដើមភាគតិច, វិបត្តិចំពោះមុខរបស់ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា ៖ ការដាក់ស្នើដោយជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាទៅកាន់កិច្ចប្រជុំតំបន់អាស៊ីរបស់វេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីពីបញ្ហារបស់ជនជាតិដើមភាគតិច នៅប្រទេសម៉ាឡេស៊ី នៅថ្ងៃទី ៤-៦ ខែមិនាឆ្នាំ២០០៩ ។ ម៉ាឡេស៊ី ២០០៩។

អង្គការពលកម្មអន្តរជាតិ **(ILO)** និងមជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់, ជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ក្រុងហ្សឺណែវ៖អង្គការ **ILO,** ឆ្នាំ ២០០៥។

ព្រះរាជាណាចក្រកម្ពុជា-ច្បាប់ស្តីពីការអប់រំ- នស/រកម **/**១២០៧/០៣២ ឆ្នាំ ២០០៧

**--------------------------**ច្បាប់ភូមិបាល- នស/រកម **/** ០៨០១/១៤ ឆ្នាំ ២០០១

**--------------------------**អនុក្រឹត្យលេខ ១១៨ អនក្រ/បក ការគ្រប់គ្រងដីរដ្ឋ ឆ្នាំ ២០០៥

**--------------------------**អនុក្រឹត្យលេខ ១៤៦ អនក្រ/បក សម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥

**----------------**អនុក្រឹត្យលេខ ៨៣ អនក្រ/បក នីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើម ឆ្នាំ ២០០៩

**Middleborg, John** ។ គម្រោងអប់រំកុមារតំបន់ភ្នំ៖ គម្រោងសាកល្បងស្តីពីការអប់រំពីរភាសានៅកម្ពុជា។ បាងកក៖ អង្គការ **UNESCO** ឆ្នាំ២០០៥

ក្រសួងអប់រំ យុវជន និងកីឡា-ស្ថិតិនិងសូចនាករនៃការអប់រំ ២០១២/២០១៣។ ភ្នំពេញ៖ ក្រសួងអប់រំ ឆ្នាំ២០១៣

**---------------------------------**ផែនការយុទ្ធសាស្ត្រ ២០០៩-២០១៣ របស់ក្រសួងអប់រំ-ផែនការយុទ្ធសាស្ត្រស្តីពីការអប់រំ ២០០៩-២០១៣។ ភ្នំពេញ៖ ក្រសួងអប់រំ ឆ្នាំ២០១០

**http://www.moeys.gov.kh/images/moeys/policies-and-strategies/policies-and-strategies/Education-Strategic-Plan-2009-2013/esp-2009-2013-en.pdf**

**----------------------------------**គោលនយោបាយស្តីពីការអប់រំក្រៅប្រព័ន្ធ។ ភ្នំពេញ៖ក្រសួងអប់រំ ឆ្នាំ ២០០២

ក្រសួងសុខាភិបាល ផែនការយុទ្ធសាស្ត្រផ្នែកសុខាភិបាល ២០០៨-២០១៥។ ភ្នំពេញ៖ ក្រសួងសុខាភិបាល ឆ្នាំ ២០០៨

ក្រសួងផែនការ។ បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ។ ភ្នំពេញ៖ ក្រសួងផែនការឆ្នាំ ២០០៩

វិទ្យាស្ថានជាតិស្ថិតិ និងអគ្គនាយកដ្ឋានសុខាភិបាល។ *ការស្ទង់មតិស្តីពីសុខភាពនិងប្រជាសាស្ត្ររបស់កម្ពុជា ឆ្នាំ២០១០*។ ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១១

វេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, *"ជនជាតិដើមភាគតិចនៅកម្ពុជា"* ។ ភ្នំពេញ៖ វេទិការអង្គការនៃមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ឆ្នាំ២០០៦

**Jan Noorlander,** "បទសម្ភាសន៍ស្តីពីបញ្ហាសិទ្ធិជនជាតិដើមភាគតិច ជាមួយអ្នកសម្របសម្រួលកម្មវិធីស្តីពីជនជាតិដើមភាគតិចដែលពុំត្រូវបានយកចិត្តទុកដាក់ របស់អង្គការ**CARE**កម្ពុជា ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៤

ប្រទេសកម្ពុជាការអភិវឌ្ឍដោយបើកចំហ "អត្រាអក្ខរកម្មក្នុងឆ្នាំ២០១១" ភ្នំពេញ៖ ការអភិវឌ្ឍដោយបើកចំហឆ្នាំ ២០១៣ ។
**http://www.opendevelopmentcambodia.net/download/maps/atlas/en/Literacy-Rates-in-2011.jpg.**

ប្រទេសកម្ពុជាការអភិវឌ្ឍដោយបើកចំហ "ផែនទី សេដ្ឋកិច្ចសង្គម នៃប្រទេសកម្ពុជា" ឆ្នាំ ២០១៤
**http://www.opendevelopmentcambodia.net/maps/.**

មូល ផាត និងសុវឌ្ឍនា សេង កំណត់ត្រាបច្ចេកទេសទូទាំងប្រទេស ស្តីពីបញ្ហាជនជាតិដើមភាគតិច៖ ព្រះរាជាណាចក្រ កម្ពុជា។ ទីក្រុងរ៉ូម៖ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម ឆ្នាំ ២០១២

សម្តេចតេជោ ហ៊ុន សែន, យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី **III** ។ ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជាឆ្ន២០១៣, **http://www.cambodiainvestment.gov.kh/content/uploads/2013/11/2013-Rectangular -Strategy-III- En8.pdf**

សិទ្ធិ "ការបោះឆ្នោតឆ្នាំ ២០១២ ឃុំ / សង្កាត់" ឆ្នាំ ២០១២

សុរិយាប្រាសាទស៊ូប៊ែឌី របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា៖ ការវិភាគពីសិទ្ធិមនុស្សនៃសម្បទានដីសេដ្ឋកិច្ច និងដីសម្បទានផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ ទីក្រុងញូវយ៉ក៖ មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ២០១២, **http://daccess-dds-ny.un.org/doc/UNDOC/GEN/G12/175/03/PDF/G1217503. pdf?OpenElement.**

សិទ្ធិ "ការបោះឆ្នោតឆ្នាំ ២០១២ ឃុំ / សង្កាត់" ឆ្នាំ ២០១២

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ការវាយតម្លៃនិងរបាយការណ៍ចុងក្រោយស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១២។ ភ្នំពេញ៖ ខុមហ្វ្រែលឆ្នាំ ២០១២

សិទ្ធិជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា។ ទីក្រុងញូវយ៉កៈ វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាឆ្នាំ ២០១០

អង្គការ**UNICEF, Cambodia Country Kit 2011-2015, (**ភ្នំពេញៈ អង្គការ **UNICEF** កម្ពុជា ឆ្នាំ ២០១១**)[http://www.unicef.org/cambodia/results_for_children_18255.html](http://www.unicef.org/cambodia/results_for_children_18255.html).**

**Diana Vinding** និងការិយាល័យពលកម្មអន្តរជាតិ**, “**ទស្សនវិស័យពីបណ្តាសហគមន៍នានានៅប្រទេសបូលីវី កម្ពុជា កាមេរូន ក្វាតេម៉ាឡា និងណេប៉ាល់៖ ជនជាតិដើមភាគតិច និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍",  ។ ហ្សឺណែវៈ អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០៦

“សិក្ខាសាលាស្តីពីការអប់រំពហុភាសានៅកម្ពុជា” ដកស្រង់ព័ត៌មាននៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៤ **http://www.moeys.gov.kh/en/minister-page/423.html.**